00189177

C22/I/32

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣)
បញ្ជូនទៅ៖ អង្គបុរេជំនុំជម្រះ
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨
ភាគីបញ្ជូន៖ ការិយាល័យសហព្រះរាជអាជ្ញា
ភាសាដើម៖ អង់គ្លេស
ប្រភេទឯកសារ៖ សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 05 / 2008
ម៉ោង (Time/Heure): 14:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា
## នៅនឹងសារណារបស់ អៀង សារី ជំទាស់នឹងបញ្ជាឃុំខ្លួនបណ្ដោះអាសន្ន

---

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**

**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្ដីរបស់ អៀង សារី៖**
លោក អាង ឧត្ដម
លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

00189178



## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា ស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវសារណារបស់ជនត្រូវចោទ អៀង សារី ដែលថា អ.វ.ត.ក គ្មានយុត្តាធិការក្នុងការស៊ើបអង្កេត ឬចោទប្រកាន់លើរូបគាត់ ដោយឈរលើមូលដ្ឋាននៃ ការជំនុំជម្រះក្តីឆ្នាំ១៩៧៩ ដោយ*កំបាំងមុខ* របស់គាត់ និងការលើកលែងទោស និងការអនុគ្រោះទោសពីព្រះមហាក្សត្រ នៅឆ្នាំ១៩៩៦[1] ។

## ២. ប្រវត្តិអង្គហេតុដែលពាក់ព័ន្ធ

២. ក្រោយការផ្តួលរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រកាសឲ្យប្រើនូវក្រឹត្យច្បាប់ លេខ១ ("ក្រឹត្យច្បាប់") ដែលបង្កើតឲ្យមានតុលាការប្រជាជនបដិវត្តន៍កម្ពុជា (PRT) ដើម្បី "កាត់សេចក្តីទៅលើអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តដោយពួកបនក្បត់ ប៉ុល ពត - អៀង សារី"[2] ។ PRT បានចោទប្រកាន់ផ្តន្ទាទោស និងកាត់ទោសជនត្រូវចោទនេះ*ដោយកំបាំងមុខ* ។ បទចោទប្រកាន់ដែលបានចោទទៅលើជននេះ គឺអំពើប្រល័យពូជសាសន៍ នៅក្រោមក្រឹត្យច្បាប់ និងនៅក្រោមអនុសញ្ញា ស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ១៩៤៨ (អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍)[3] ។ PRT បានកាត់ទោសជននេះឲ្យទទួល

---

[1] *ករណីរបស់ អៀង សារី,* សារណារបស់លោក អៀង សារី អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវីសុំការ ពន្យារពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣), ចុះថ្ងៃទី០៧ មេសា ២០០៨ [*បន្ទាប់ពីនេះទៅហៅថា៖* "សារណា"] ។

[2] ក្រឹត្យច្បាប់លេខ១៖ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តន៍នៅភ្នំពេញដើម្បីជំនុំជម្រះបន ប៉ុល ពត - អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា, ចុះថ្ងៃទី១៥ កក្កដា ១៩៧៩ [*បន្ទាប់ពីនេះទៅហៅថា៖* "ក្រឹត្យច្បាប់"] នៅក្នុង *អំពើប្រល័យពូជសាសន៍នៅកម្ពុជា - ឯកសារពីការកាត់ទោស ប៉ុល ពត និង អៀង សារី,* ការផ្សាយរបស់សាកលវិទ្យាល័យ Pennsylvania, Philadelphia, ឆ្នាំ២០០០ [*បន្ទាប់ពីនេះទៅហៅថា៖* "អំពើប្រល័យពូជសាសន៍នៅកម្ពុជា"] ។

[3] អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

ទោសប្រហារជីវិត និងបានបង្គាប់ឱ្យរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់ជននេះ[4] ។ ជននេះមិនធ្លាប់បានអនុវត្តទោសនេះទេ ។

៣. នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ("ច្បាប់ដាក់ឱ្យនៅក្រៅច្បាប់")[5] ។ ច្បាប់នេះ បានចាត់ចូលជាបទឧក្រិដ្ឋនូវសមាជិកនៃ "អង្គការនយោបាយ និងកងកម្លាំងយោធារបស់ក្រុមកម្ពុជាប្រជាធិបតេយ្យ"[6] ។ តាមរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រមានអំណាចដើម្បីផ្តល់ឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសសំរាប់ជនទាំងឡាយណាដែលបានរំលោភច្បាប់នេះ[7] ។ នៅពេលចុះចូលនៃជនត្រូវចោទពីខ្មែរក្រហមក្នុងឆ្នាំ១៩៩៦ ព្រះមហាក្សត្របានផ្តល់ឱ្យគាត់នូវការអនុគ្រោះទោសចំពោះការដាក់ទោសដោយ PRT និងការលើកលែងទោសចំពោះ ការចោទប្រកាន់ណាមួយនៅពេលអនាគត នៅក្រោមច្បាប់ដាក់ឱ្យនៅក្រៅច្បាប់[8] ។

៤. ច្បាប់ អ.វ.ត.ក ចែងថា តុលាការនេះត្រូវសម្រេចអំពីវិសាលភាពនៃការលើកលែងទោស ឬការអនុគ្រោះទោសណាមួយ ដែលបានផ្តល់នៅមុនការអនុម័តច្បាប់នេះ[9] ។ ស្របគ្នានេះដែរ ខណៈពេលដែលធ្វើការសម្រេចនៅលើបញ្ហានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតបានសម្រេចអំពីផលប៉ះពាល់នៃការកាត់ទោសក្នុងឆ្នាំ១៩៧៩ ដោយ PRT និងការលើកលែងទោស និងការអនុគ្រោះទោសដោយព្រះមហាក្សត្រ ទៅលើលទ្ធភាពរបស់តុលាការនេះដើម្បីចោទប្រកាន់ទៅលើគាត់ ។ ពួកគេបានសម្រេចថា (១) គោលការណ៍ *គ្មាន*

---

[4] អំពើប្រល័យពូជសាសន៍នៅកម្ពុជា, សាលក្រម ។

[5] ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ០១.នស.៩៤ ចុះថ្ងៃទី១៥ កក្កដា ១៩៩៤, *អាចរកបានតាមវ៉ិបសាយ៖* http://www.cambodia.org.kh/krt/pdfs/Law%20to%20Outlaw%20DK%20Group%20 1994.pdf [*បន្ទាប់ពីនេះទៅហៅថា៖* "ច្បាប់ស្តីពីការដាក់ឱ្យនៅក្រៅច្បាប់"] ។

[6] ច្បាប់ស្តីពីការដាក់ឱ្យនៅក្រៅច្បាប់, មាត្រា ២ ។

[7] ច្បាប់ស្តីពីការដាក់ឱ្យនៅក្រៅច្បាប់, មាត្រា ៧ ។ ច្បាប់នេះបានរំលឹកឡើងវិញ អំពីអំណាចរបស់ព្រះមហាក្សត្រតាមច្បាប់រដ្ឋធម្មនុញ្ញ ក្នុងការអនុគ្រោះទោស និង ការលើកលែងទោស ។

[8] សារណា, កថាខណ្ឌទី ៦ ។

[9] ច្បាប់ អ.វ.ត.ក, មាត្រា ៤០ ។

*ការកាត់ក្តីពីរដងចំពោះមនុស្សដដែលសំរាប់បទល្មើសដដែល* (ការកាត់ក្តីពីរដង) មិនអនុវត្តទេ ព្រោះតុលាការនេះ មិនទាន់បានចោទប្រកាន់ជនត្រូវចោទនេះអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍នៅឡើយ ដែលជាបទល្មើសតែមួយគត់ដែល តុលាការប្រជាជនបដិវត្តន៍ បានកាត់ទោសគាត់ និង (២) ព្រះរាជក្រឹត្យ មិនរារាំងដល់ការចោទប្រកាន់ចំពោះគាត់សំរាប់បទឧក្រិដ្ឋណាមួយដែលស្ថិតនៅក្រោមយុត្តាធិការនៃតុលាការនេះឡើយ[10] ។

## ៣. ការកាត់ក្តីពីរដងមិនអាចអនុវត្តបានទេ

### សេចក្តីផ្តើម

៥. ដោយផ្អែកទៅលើគោលការណ៍នៃការកាត់ក្តីពីរដង ជនត្រូវចោទអះអាងថា ការដាក់ទោសរបស់គាត់ដោយ PRT ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បានប្លុកបញ្ចូលក្នុងបទចោទប្រកាន់ទាំងអស់ដែលតុលាការនេះកំពុងស៊ើបអង្កេតប្រឆាំងនឹងរូបគាត់ និងដូច្នេះហើយ ការស៊ើបសួរ និងការចោទប្រកាន់ណាមួយនៅចំពោះមុខតុលាការនេះ ត្រូវបានរារាំង[11] ។ គាត់ទាមទារថា តាមច្បាប់កម្ពុជា គ្មានការលើកលែងឡើយសំរាប់គោលការណ៍នៃការកាត់ក្តីពីរដង និងប្រសិនបើមាន គោលការណ៍នេះក៏មិនអនុវត្តដែរ[12] ។ គាត់តវ៉ាថា ច្បាប់ជាធរមានហាមឃាត់ការចោទប្រកាន់បន្ថែមពីលើបទល្មើសខុសគ្នាដែលកើតចេញពីអំពើតែមួយដូចគ្នា - ជាពិសេស បើសិនបទចោទនោះកើតចេញពីសវនាការជំនុំជម្រះក្តីពីរក្នុងពេលដាច់ដោយឡែកពីគ្នា និងបើសិនបទចោទពីមុនប្លុកបញ្ចូលក្នុងបទចោទលើកក្រោយ[13] ។

---

[10] *ករណីរបស់ កាំង ហ្គេកអ៊ាវ,* ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី ៣១ កក្កដា ២០០៧, កថាខណ្ឌទី ១០-១៤ [*បន្ទាប់ពីនេះទៅហៅថា៖* "ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន"] ។

[11] សារណា, កថាខណ្ឌទី ៩.៤ ។

[12] សារណា, កថាខណ្ឌទី ៩.១ ។

[13] សារណា, កថាខណ្ឌទី ៩.២ - ៩.៤ ។

00189181

C22/I/132

៦. សហព្រះរាជអាជ្ញាស្នើឲ្យអង្គបុរេជំនុំជម្រះ បដិសេធទៅលើអំណះអំណាងទាំងនេះ ។ គោលការណ៍នៃការកាត់ក្តីពីរដង មិនអាចយកមកអនុវត្តបានទេក្នុងករណីនេះដោយសារ PRT មិនបានអនុលោមតាមបទដ្ឋាននៃការជំនុំជម្រះក្តីត្រឹមត្រូវ ។ ការលើកលែងចំពោះគោលការណ៍គ្មានការកាត់ក្តីពីរដង គឺមិនមានចែងច្បាស់លាស់ទេនៅក្នុងច្បាប់កម្ពុជា ឬតាមជម្រើសផ្សេងពីនេះ គួរតែត្រូវបានអនុវត្តស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមរម្យនៃច្បាប់[14] ។ ជាងនេះទៅទៀត បើសិនការជំនុំជម្រះក្តីត្រូវបានធ្វើឡើងស្របតាមបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះក្តីត្រឹមត្រូវ នោះគោលការណ៍នៃការកាត់ក្តីពីរដង នឹងមិនរារាំងដល់ការចោទប្រកាន់នៃបទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍ឡើយ ដូចដែលបានទទួលស្គាល់នៅក្រោមច្បាប់អន្តរជាតិ ឬសំរាប់ឧក្រិដ្ឋកម្មដទៃទៀតដែលស្ថិតនៅក្រោមច្បាប់ អ.វ.ត.ក ។ ការចោទប្រកាន់ថែមពីលើសំរាប់បទល្មើសខុសគ្នាដែលកើតចេញពីអំពើតែមួយដដែល គឺមិនបានហាមឃាត់ទេនៅក្រោមច្បាប់អន្តរជាតិ បើសិនមានភាពមិនត្រឹមត្រូវណាមួយដែលកើតឡើងត្រូវបានគេយកមកគិតគូរនៅពេលធ្វើការកាត់ទោស ។

## អំពីច្បាប់

៧. មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (“ICCPR”) ដែលអនុវត្តនៅចំពោះមុខតុលាការនេះ ហាមឃាត់ការកាត់ក្តីពីរដង[15] ។ ICCPR តម្រូវថា គ្មានជនណាម្នាក់ត្រូវបានគេកាត់ទោស ឬត្រូវបានផ្តន្ទាទោសជាថ្មីម្តងទៀតសំរាប់បទល្មើសដែលគាត់ធ្លាប់បានគេកាត់ទោស ឬដោះលែងឲ្យរួចខ្លួន *ជាស្ថាពររួចហើយ* ស្របតាមច្បាប់នោះឡើយ[16] ។ គោលបំណងនៃគោលការណ៍នេះ គឺដើម្បីទុកឲ្យបុគ្គលម្នាក់រួចចាកផុតពីការទទួលរង លើសពីមួយលើក នូវភាពតានតឹងផ្លូវចិត្ត ផ្លូវអារម្មណ៍ ខាងផ្លូវកាយ និងថវិកា ដែលបានជាប់ជំពាក់

---

[14] កិច្ចព្រមព្រៀង អ.វ.ត.ក, មាត្រា ១២ ។

[15] ច្បាប់ អ.វ.ត.ក, មាត្រា ៣៣ (ថ្មី) ។

[16] ICCPR, មាត្រា ១៤.៧ ។

ទៅនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ[17] ។ ប៉ុន្តែ គោលការណ៍នេះស្ថិតនៅក្រោមការលើកលែងមួយចំនួន[18] ។ នៅក្នុងការជំនុំជម្រះក្តីលើកទីមួយ គោលការណ៍នេះអនុវត្តនៅពេល៖

(i) តុលាការ មិនបានអនុវត្តតាមឱ្យបានពេញលេញនូវវិធានការការពារជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយត្រឹមត្រូវ ឬមិនបានធ្វើសកម្មភាពដោយឯករាជ្យ ឬមិនលំអៀង ។

(ii) តុលាការបានធ្វើការជំនុំជម្រះ ដើម្បីបិទបាំងជនជាប់ចោទពីការទទួលខុសត្រូវព្រហ្មទណ្ឌអន្តរជាតិ ។

(iii) អយ្យការ ឬតុលាការមិនបានធ្វើសកម្មភាពប្រកបដោយវីរយភាព ដែលបានទទួលស្គាល់ដោយបទដ្ឋានអន្តរជាតិ, ឬ

(iv) ចុងចោទត្រូវបានចោទប្រកាន់ចំពោះអង្គហេតុ ឬអំពើដូចគ្នា ប៉ុន្តែបទឧក្រិដ្ឋនោះមានចរិតលក្ខណៈជាបទល្មើសធម្មតា ដែលមិនមែនជាបទឧក្រិដ្ឋអន្តរជាតិណាមួយ ក្នុងគោលបំណងដើម្បីបញ្ចៀស ដោយចេតនាឱ្យជ្រះស្រឡះពីស្លាកស្នាមទុយស៍ និងការជាប់ជំពាក់ទៅនឹងបទឧក្រិដ្ឋអន្តរជាតិ[19] ។

---

[17] *រដ្ឋអាជ្ញា ទល់នឹង Aleksovski,* អគ្គបទប្រតិចារឹក, សំណុំរឿងលេខ IT-95-14/1, ចុះថ្ងៃទី២៤ មីនា ២០០០ ។ *ករណីរបស់ Green ទល់នឹង ប្រទេសសហរដ្ឋអាមេរិក,* ៣៥៥ ស.រ.អា ១៨៤ (ឆ្នាំ១៩៥៧), កថាខណ្ឌទី ១៨៧-៨៨ ។

[18] អនុសញ្ញាស្តីពីសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប, មាត្រា ៤, ឯកសារពិធីការទី ៧ ។ លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ២០.៣ ។

[19] Antonio Cassese, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, ការផ្សាយរបស់សាកលវិទ្យាល័យ Oxford, ឆ្នាំ២០០៣, ទំព័រទី ៣១៩-៣២១ ។ [*បន្ទាប់ពី នេះទៅហៅថា៖* "សៀវភៅរបស់ Cassese"] ។ សូមមើលផងដែរ៖ ពិធីការលេខ ៧ អំពីអនុសញ្ញាសម្រាប់ទ្វីបអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, E.T.S 117, មាត្រា ៤.២, ចូលជាធរមាននៅថ្ងៃទី០១ វិច្ឆិកា ១៩៨៨ ។ កម្មវិធីច្បាប់ និងកិច្ចការសាធារណៈ របស់សាកលវិទ្យាល័យ Princeton, គោលការណ៍ Princeton ស្តីពីយុត្តាធិការសាកលចំនួន ២៨ យ៉ាង ។ គោលការណ៍ទី ៩៖ Ne bis in idem/Double Jeopardy (អាជ្ញាអស់ជំនុំ) (ឆ្នាំ២០០១), *អាចរកបានតាម៖* HTUhttp://wwwl.umn.edu/humanrts/instree/princeton.htmlUTH ។

## *តុលាការត្រូវតែលើកស្ទួយបទដ្ឋាននៃការជំនុំជម្រះក្តីដោយត្រឹមត្រូវ*

៨. ដោយធ្វើការឆ្លុះបញ្ចាំងពីភាពភ្លឺថ្លាដូចកែវចរណៃនៃច្បាប់អន្តរជាតិ លក្ខន្តិកៈនៃតុលាការអន្តរជាតិចែងថា ការកាត់ទោសពីរដងមិនអនុវត្តឡើយ ប្រសិនបើតុលាការអន្តរជាតិធ្វើការចោទប្រកាន់លើកទីពីរ បន្ទាប់ពីការចោទប្រកាន់លើកទីមួយនៅថ្នាក់ជាតិ បានធ្វើឡើងដោយ "មិនឯករាជ្យ និងមិនលំអៀង ស្របតាមនិយាមស្តីពីដំណើរការសមរម្យ ដែលបានទទួលស្គាល់ជាអន្តរជាតិ ឬ ដែលបានធ្វើឡើងតាមរបៀបមួយដែលមិនស៊ីសង្វាក់គ្នាទៅនឹងបំណងក្នុងការនាំខ្លួនជនជាប់ចោទមករកយុត្តិធម៌[20] ។ ICCPT ចែងអំពីនិយាមនៃដំណើរការត្រឹមត្រូវតាមនីតិវិធីច្បាប់ ដោយរាប់បញ្ចូលនូវ (១) សិទ្ធិទទួលបាននូវសវនាការជាសាធារណៈ និងត្រឹមត្រូវដោយតុលាការមួយដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង *ដែលបានបង្កើតឡើងដោយច្បាប់*[21] ។ (២) សិទ្ធិទទួលបានការសន្មត់ថាគ្មានទោសដរាបណាមិនទាន់រកឃើញថាមានទោស[22] ។ (៣) សិទ្ធិឲ្យគេពិនិត្យសើរើឡើងវិញអំពីការកាត់ឲ្យជាប់ទោសដោយ*តុលាការថ្នាក់ខ្ពស់ជាងណាមួយ*[23] ។ល។

៩. ICCPR ចែងផងដែរថា ចុងចោទមានសិទ្ធិឲ្យគេជំនុំជម្រះក្តីដោយមានវត្តមានរបស់ខ្លួន[24] ។ ស្របគ្នានេះដែរ តាមច្បាប់កម្ពុជា ការកាត់ឲ្យជាប់ទោស *ដោយកំបាំងមុខ* ត្រូវបានគេទុកមួយឡែកសិន នៅពេលចុងចោទត្រូវបានចាប់ខ្លួន ឬបានចុះចូលតាមការស្ម័គ្រចិត្ត ។ ការជំនុំជម្រះក្តីជាថ្មីនឹងធ្វើតាមក្រោយ[25] ។ ដោយសារការជំនុំជម្រះក្តីជាថ្មីនេះ ការកាត់ឲ្យជាប់ទោសពីមុន

---

[20] លក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់ ICC, មាត្រា ២០.៣.ខ ។ លក្ខន្តិកៈសម្រាប់ ICTY, មាត្រា ១០ ។ លក្ខន្តិកៈសម្រាប់ ICTR, មាត្រា ៩ ។ លក្ខន្តិកៈ សម្រាប់ SCSL, មាត្រា ៩.២.ខ ។

[21] ICCPR, មាត្រា ១៤.១ ។

[22] ICCPR, មាត្រា ១៤.២ ។

[23] ICCPR, មាត្រា ១៤.៥ ។

[24] ICCPR, មាត្រា ១៤.៣.ឃ ។

[25] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៤១០, ៤១២, ៤៨៩-៤៩៣ ។ សូមមើលជាឧទាហរណ៍៖ គណៈកម្មាធិការនៃក្រុមប្រឹក្សារដ្ឋមន្ត្រីសម្រាប់ទ្វីបអឺរ៉ុប, សេចក្តីសម្រេច (៧៥)១១ របស់គណៈកម្មាធិការនៃរដ្ឋមន្ត្រី ស្តីពីលក្ខណវិនិច្ឆ័យសម្រាប់គ្រប់គ្រងលើដំណើការនីតិវិធី ដែលត្រូវងនុវត្តក្នុងពេលអវត្តមានរបស់ជនត្រូវចោទ (ចុះថ្ងៃទី២១ ឧសភា ១០៧៥), *អាចរកបានតាម៖*

មិនត្រូវបានគេពិចារណាថា *ជាស្ថាពរ* នោះឡើយ ។ ហេតុដូច្នេះហើយបានជាចុងចោទមិនអាចទាមទារការកាត់ក្តីពីរដងបានឡើយ[26] ។

*ការកាត់សេចក្តីពីបទឧក្រិដ្ឋខុសគ្នាដែលមានដើមកំណើតចេញពីអំពើតែមួយដដែល ត្រូវបានអនុញ្ញាត*

១០. ការកាត់សេចក្តីលើកទីពីររបស់ចុងចោទចំពោះបទឧក្រិដ្ឋខុសគ្នា ដោយឈរលើមូលដ្ឋាននៃអំពើព្រហ្មទណ្ឌតែមួយដដែល មិនរំលោភទៅលើគោលការណ៍នៃការកាត់ក្តីពីរដងនោះទេ ឲ្យតែមានភាពមិនត្រឹមត្រូវណាមួយដែលភាយចេញពីការកាត់ទោសទ្វេរដង ត្រូវបានគេយកជាប្រយោជន៍សំរាប់ការដាក់ទោស ។ តុលាការអន្តរជាតិ អនុញ្ញាតឲ្យមានការកាត់ទោសច្រើនដងសំរាប់អំពើតែមួយដដែល (ឬការខកខាន) ដែលបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការរំលោភលើបទបញ្ញត្តិខុសៗគ្នាជាច្រើននៃច្បាប់លក្ខន្តិកៈសំរាប់ធ្វើការចោទប្រកាន់ មានន័យថា បទប្បញ្ញត្តនីមួយៗដែលមានធាតុផ្សំខុសៗគ្នា ដែលតម្រូវឲ្យមានការបង្ហាញភស្តុតាងបញ្ជាក់ពីអង្គហេតុខុសៗគ្នា ។ ការកំណត់ថាតើបទបញ្ញត្តនីមួយៗមានធាតុផ្សំនៃភស្តុតាងខុសៗគ្នាយ៉ាងណានោះគឺជាបញ្ហាផ្នែកអង្គច្បាប់[27] ។ ជាពិសេសតាមការអនុវត្តន៍ជាក់ស្តែង ការពិតដែលថាអំពើដូចគ្នាដែលជាញឹកញាប់គាំទ្រដល់ការរកឃើញថា ជនជាប់ចោទមានបំណងប្រព្រឹត្តិទាំងអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិជាក់លាក់នោះ មិនបានធ្វើឲ្យបំណងទាំងពីរត្រូវតែដូចគ្នាបេះបិទទេ នៅក្នុងច្បាប់[28] ។

HTUhttp://cm.coe.int/ta/res/1975/75x11.htmlUTH (ដែលបានចែងថា ជនណាមួយដែលត្រូវបានកាត់ក្តីដោយកំបាំងមុខ មានសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីឡើងវិញ ទោះបីជាជននោះបានទទួលដីកាកោះដោយត្រឹមត្រូវក៏ដោយ បើសិនជាគាត់អាចបង្ហាញសំអាងបានថា អវត្តមានរបស់គាត់និងការខកខានមិនបានជូនដំណឹងដល់ចៅក្រមបណ្តាលមកពីហេតុផលហួសពីការឃុំគ្រងរបស់គាត់ )

[26] ICCPR, មាត្រា ១៤.៧ ។ *រដ្ឋអាជ្ញា ទល់នឹង Semanza,* សេចក្តីសម្រេច, សំណុំរឿងលេខ ICTR-97-20-A, ចុះថ្ងៃទី៣១ ឧសភា ២000, កថាខណ្ឌទី ៧៤ ។

[27] *រដ្ឋអាជ្ញា ទល់នឹង Kordic និង Cerkez,* សាលដីកា, សំណុំរឿងលេខ IT-95-14/2-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី ១៧ ធ្នូ ២00៤, កថាខណ្ឌទី ១0៣៣ [*បន្ទាប់ពីនេះទៅហៅថា៖* “សាលដីកាសម្រេចលើករណីរបស់ Kordic និង Cerkez”] ។

[28] *រដ្ឋអាជ្ញា ទល់នឹង Krstic,* សាលដីកា, សំណុំរឿងលេខ IT-98-33-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី១៩ មេសា ២00៤, កថាខណ្ឌទី ២២៦ [*បន្ទាប់ពីនេះទៅហៅថា៖* “សាលដីកាសម្រេចលើករណីរបស់ Krstic”] ។

១១. នៅក្នុងរឿងក្តីរបស់ *Delalic,* តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គូស្លាវី ("ICTY") បានសម្រេចថា ការកាត់ទោសច្រើនដងដោយឈរលើឈុតនៃអង្គហេតុដូចគ្នាដែលបានបង្ហាញរួចហើយ អាចត្រូវបាន "យកតាម ដោយមានបញ្ហាជាសក្តានុពលនៃភាពមិនត្រឹមត្រូវចំពោះជនជាប់ចោទ ដែលបាននឹងកំពុងលើកឡើងនៅដំណាក់កាលកាត់ទោស"[29] ។ ករណីជាច្រើនផ្សេងទៀតនៅចំពោះមុខតុលាការអន្តរជាតិ ក៏បានសម្របខ្លួនទៅតាមការសាកល្បងនៃធាតុផ្សំដូចគ្នានេះដែរ[30] ។ តុលាការសិទ្ធិមនុស្សសហគមន៍អឺរ៉ុបនៅ *Oliveira*[31] ហើយនិងតុលាការកំពូលសហរដ្ឋអាមេរិកនៅ *Blockburger* ក៏បានអនុវត្តតាមការសាកល្បងនេះដែរ[32] ។

១២. គោលការណ៍នេះបំរើឱ្យគោលបំណងភ្លោះ ។ គឺគោលការណ៍ធានាឱ្យប្រាកដថា ចុងចោទត្រូវបានកាត់ទោសចំពោះតែបទល្មើសដែលខុសៗគ្នាតែប៉ុណ្ណោះ និងធានាថាការកាត់ទោសនោះ ឆ្លុះបញ្ចាំងពេញលេញអំពីឧក្រិដ្ឋភាពរបស់គាត់[33] ។ ការកាត់ទោសច្រើនដងធ្វើឡើងដើម្បីរៀបរាប់ឱ្យបានពេញលេញអំពីពិរុទ្ធភាពរបស់ចុងចោទ និងដើម្បីផ្តល់នូវរូបភាពឱ្យបានពេញលេញនៃអំពើព្រហ្មទណ្ឌរបស់គាត់[34] ។

---

[29] *រដ្ឋអាជ្ញា ទល់នឹង Delalic,* សាលដីកា, សំណុំរឿងលេខ IT-96-21-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២០ កុម្ភៈ ២០០០, កថាខណ្ឌទី ៤០៥ ។

[30] *រដ្ឋអាជ្ញា ទល់នឹង Kupreskic និងគូកន,* សាលក្រម, សំណុំរឿងលេខ IT-95-16-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី១៤ មករា ២០០០, កថាខណ្ឌទី ៧១៨ ។ *រដ្ឋអាជ្ញា ទល់នឹង Akayesu,* សាលក្រម, សំណុំរឿងលេខ ICTR-96-4-T, អង្គជំនុំជម្រះសាលាដំបូងនៃ តុលាការ ICTR, ចុះថ្ងៃទី០២ កញ្ញា ១៩៩៨, កថាខណ្ឌទី ៤៦៨ ។

[31] *ករណីរបស់ Oliveira ទល់នឹង ប្រទេសស្វីស,* 25711/94 [1998] ECHR 68 ។ នេះគឺជាទស្សនៈចង្អៀតចង្អល់មួយជាងអ្វីដែល ECHR បាន អនុម័តនៅក្នុង *ករណីរបស់ Gardinger ទល់នឹង ប្រទេសអូទ្រីស,* 15963/90 1995 [ECHR] 36 ដែលគេបានរកឃើញថាមានការរំលោភលើ មាត្រា ៤ ពីព្រោះបទចោទទាំងពីរ ធ្វើឡើងតាមមូលដ្ឋាននៃការប្រព្រឹត្តិដូចគ្នា ។

[32] *ករណីរបស់ Blockburger ទល់នឹង ប្រទេសសហរដ្ឋអាមេរិក,* 284 US 299, 304 (1932) ។

[33] សាលដីកាសម្រេចលើករណីរបស់ Kordic និង Cerkez, កថាខណ្ឌទី ១០៣៣ ។

[34] សាលដីកាសម្រេចលើករណីរបស់ Krstic, កថាខណ្ឌទី ២១៧ ។

## សេចក្តីសំអាង

### *(១) តុលាការប្រជាជនបដិវត្តន៍មិនបំពេញតាមបទដ្ឋានអន្តរជាតិ*

១៣. តុលាការប្រជាជនបដិវត្តន៍ មិនបានធ្វើត្រូវតាមការការពារនៃការកាត់ក្តីដ៏ត្រឹមត្រូវតាមគោលការណ៍អន្តរជាតិនោះទេ[35] ។ ទីមួយគេបានបង្កើតតុលាការនេះឡើងដោយក្រឹត្យច្បាប់ ដែលមិនត្រូវបានប្រកាសឱ្យប្រើដោយអង្គនីតិបញ្ញត្តិមួយឡើយ[36] ។ ជាការបន្ថែម ចៅក្រមមួយរូបបានដាក់ជូននូវចម្លើយសាក្សីមួយប្រឆាំងនឹងជនជាប់ចោទ[37] ។ ចម្លើយសាក្សីទាំងឡាយច្រើនតែមានសរសេរពីស្វាមីភក្តិនានាចំពោះរដ្ឋាភិបាល[38] ។ តុលាការប្រជាជនបដិវត្តន៍ ត្រូវបានកំហិតដោយសារអាគារកាត់ក្តីមានលក្ខណៈមិនគ្រប់គ្រាន់យ៉ាងខ្លាំង ។ ជាលទ្ធផលសវនាការមានរយៈពេលតែប្រាំថ្ងៃប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងការកាត់ក្តីពីបទប្រល័យពូជសាសន៍ដទៃទៀតក្នុងប្រវត្តិសាស្ត្រ ដែលមានរយៈពេលរហូតដល់ទៅរាប់ខែ ឬរាប់ឆ្នាំ[39] ។

១៤. ទីពីរ តុលាការនេះត្រូវបានបង្កើតឡើងយ៉ាងប្រញាប់ប្រញាល់ ដោយទំនងជាមានគោលបំណងតែមួយគត់គឺដើម្បី "បរិហារបន ប៉ុល ពត អៀង សារី" ឱ្យបានភ្លាមៗក្រោយពីការបណ្តេញ

---

[35] ICCPR, មាត្រា ១៤.១ ។ សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស (UDHR), មាត្រា ១០ [*បន្ទាប់ពីនេះទៅហៅថា៖* "UDHR"] ។

[36] អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៤៥ ។ ក្រឹត្យច្បាប់ត្រូវបានបង្កើតឡើងដោយអង្គនីតិប្រតិបត្តិ "ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា" ។ គឺនៅមានការខ្វះខាតក្នុងការបែងចែកអំណាចនានាសម្រាប់រដ្ឋគឺរវាង៖ អង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងអង្គតុលាការ ។ សូមមើល៖ John Quigley, *សេចក្តីផ្តើម,* អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៧ ។

[37] *ចម្លើយរបស់សាក្សីឈ្មោះ ប៉ែន ណូវុធ (Pen Nauvuth),* ចុះថ្ងៃទី២៥ មិថុនា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៩៤-៦ ។ *ក្រឹត្យច្បាប់លេខ ២៥៖ ការចាត់តាំងសមាជិកតុលាការ,* ចុះថ្ងៃទី២០ កក្កដា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៤៩-៥០ ។

[38] John Quigley, *សេចក្តីផ្តើម,* អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ១៥ ។

[39] សូមមើលជាឧទាហរណ៍៖ *រដ្ឋអាជ្ញា ទល់នឹង Krstić,* សាលក្រម, សំណុំរឿងលេខ IT-98-33-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី០២ សីហា ២០០១ ។

ពួកខ្មែរក្រហមពីអំណាច[40] ។ ទីបី តុលាការប្រជាជនបដិវត្តន៍ បានសន្មតជាមុនថា ជនជាប់ចោទមានពិរុទ្ធភាព (មិនមែនជាជនស្លូតត្រង់) នៅមុនពេលមានសាលក្រម[41] ។ បុព្វកថារបស់ក្រឹត្យនោះបានចែងថាជនជាប់ចោទ "បានសម្លាប់យ៉ាងរង្គាលនូវមនុស្សរាប់លាននាក់" ហើយថាក្រឹត្យនោះនឹងបង្កើតនូវ តុលាការប្រជាជនបដិវត្តន៍មួយ ដើម្បីធ្វើការកាត់ក្តីពីអំពើប្រល័យពូជសាសន៍ "ដែលបានប្រព្រឹត្តដោយ" បន ប៉ុល ពត - អៀង សារី[42] ។ ប្រធានតុលាការ បានប្រកាសនៅក្នុងសន្និសីទសារព័ត៌មានមួយ នៅមុនសវនាការចាប់ផ្តើមថា ជនជាប់ចោទមានពិរុទ្ធភាពពីបទ ប្រល័យពូជសាសន៍ និងអំពើឧក្រិដ្ឋផ្សេងៗទៀត[43] ។ កាលវិភាគនៃសវនាការបានចែងជាមុន ថាសាលក្រមរបស់តុលាការ នឹងត្រូវបានប្រកាសនៅថ្ងៃជាមួយគ្នានឹងថ្ងៃចេញសេចក្តីសន្និដ្ឋាន បញ្ចប់ការពិភាក្សាដេញដោល[44] ។

១៥. ទីបួន PRT មិនបានធ្វើការជំនុំជម្រះដោយមានវត្តមានពួកគេនោះទេ[45] ។ ក្រុមប្រឹក្សា ដែលបានចាត់តាំងក្នុងនាមជនជាប់ចោទមិនបានយល់ព្រមតាម ឬ បានស្វែងរកសេចក្តីណែនាំណាមួយឡើយ[46] ។ ពួកគាត់ខកខានមិនបានជំទាស់នឹងយុត្តាធិការរបស់តុលាការប្រជាជនបដិវត្តន៍ ហើយក៏មិនបានសួរដេញដោលសាក្សីរបស់ខ្លួន ឬរបស់ភាគីបដិបក្ខ ឬក៏ជំទាស់នឹងភស្តុតាងក៏ទេដែរ[47] ។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ពួកគាត់ បានទទួលយកពិរុទ្ធ

---

[40] នៅចន្លោះការប្រកាសក្រឹត្យច្បាប់នៅថ្ងៃទី១៥ កក្កដា ១៩៧៩ និង ថ្ងៃទី១៩ សីហា ១៩៧៩, ដែលជារយៈពេលប្រមាណជាមួយខែប៉ុណ្ណោះ, គេបានបង្កើតតុលាការ ធ្វើការជំនុំជម្រះក្តី និង ការកាត់ទោសបានចូលជាធរមាន ។

[41] ICCPR, មាត្រា ១៤.២ ។ UDHR, មាត្រា ១១.១ ។

[42] ក្រឹត្យច្បាប់, មាត្រា ១ ។

[43] *សន្និសីទកាសែតរបស់ កែវ ចិន្តា(Keo Chanda), រដ្ឋមន្ត្រីក្រសួងព័ត៌មាន វប្បធម៌ និងសារព័ត៌មាន និងជាប្រធានគណៈកម្មាធិការកិច្ចការច្បាប់,* ចុះថ្ងៃទី២៨ កក្កដា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៤៧ ។

[44] *កាលវិភាគជំនុំជម្រះក្តីសម្រាប់តុលាការប្រជាជនបដិវត្តន៍នៅពេលសវនាការរបស់ខ្លួន,* ចុះថ្ងៃទី១៩ សីហា ១៩៧៩, *បោះពុម្ពផ្សាយឡើងវិញនៅក្នុង* អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៦៧-៩ ។

[45] ICCPR, មាត្រា ១៤.៣.ឃ ។ UDHR, មាត្រា ១១.១ ។

[46] ICCPR, មាត្រា ១៤.៣.ឃ ។

[47] William Schabas, *កម្ពុជា៖ តើវាពិតជាអំពើប្រល័យពូជសាសន៍មែនឬ?* 23 Hum. Rights. Q. 476 92001) ។

00189188

C22 I5 132

ភាពរបស់ជនត្រូវចោទ និងអបអរសាទរចំពោះការកាត់ទោសរបស់ខ្លួន[48] ។ សូម្បីតែក្រុមប្រឹក្សាម្នាក់ក្នុងចំណោមពួកគាត់ ក៏បានដាក់ជូននូវចម្លើយសាក្សីមួយដែលប្រឆាំងនឹងជនជាប់ចោទរូបនេះដែរ[49] ។

១៦. ទីប្រាំ ការកាត់ឲ្យជាប់ទោសរបស់តុលាការប្រជាជនបដិវត្តន៍ មិនអាចចាត់ទុកថាជា *ស្ថាពរ* បានទេ ដោយសារថាក្រឹត្យច្បាប់នោះមិនបានអនុញ្ញាតឲ្យជនជាប់ចោទមានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍[50] ។ មិនអាចមានដំណើរការនីតិវិធីណាមួយជា *ស្ថាពរ* ដោយគ្មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នោះទេ[51]។ តុលាការប្រជាជនបដិវត្តន៍ គឺជាវេទិកានៃតុលាការសាលាដំបូងផង និងជាតុលាការក្រោយបំផុតផង[52] ។ ហេតុដូច្នេះហើយ សវនាការកាត់ក្តីនៃតុលាការប្រជាជនបដិវត្តន៍មិនអាចយកធ្វើជារបាំងជនជាប់ចោទ មិនឲ្យមានការកាត់ទោសនៅពេលអនាគតបានទេ ។ ទោះនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ជនត្រូវចោទមិនដែលបានទទួលរងនូវការពិបាកណាមួយផ្សារភ្ជាប់ទៅនឹងការចោទប្រកាន់ព្រហ្មទណ្ឌអ្វីមួយ ដែលនឹងធ្វើយុត្តិកម្មដល់ការរារាំងមិនឲ្យមានការកាត់ទោសនៅពេលអនាគតបានទេ ។ ការណ៍នេះ គឺវាស្របគ្នាទៅនឹងគោលការណ៍ជាមូលដ្ឋានដែលថា ការកាត់ក្តីពីរដងមិនអនុវត្តចំពោះជនជាប់ចោទណាម្នាក់ដែលការកាត់ឲ្យជាប់ទោសពីមុនរបស់គាត់ គឺជាលទ្ធផលនៃការកាត់ទោស *ដោយកំបាំងមុខ* បានទេ – គឺដូចជាថា ការជំនុំជម្រះមួយដែលគ្មានចុងចោទ មិនបង្កើតបាននូវភាពមិនត្រឹមត្រូវណាមួយដែលផ្តល់នូវសនិទានភាព (ភាពត្រឹមត្រូវតាមវិចារណញ្ញាណ) សម្រាប់ភាពអាចអនុវត្តបាននូវគោលការណ៍នោះទេ ។

---

[48] *សេចក្តីសង្ខេបច្បាប់របស់ Hope R. Stevens: ក្រុមមេធាវីការពារក្តី,* ចុះថ្ងៃទី១៩ សីហា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៥០៤-០៨ ។

[49] *ចម្លើយរបស់សាក្សីឈ្មោះ ឌិត មន្ទីរ (Dith Munty),* ចុះថ្ងៃទី២២ ឧសភា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ១៣៤-៣៨ ។ *សេចក្តីសម្រេចលេខ ២៥៖ ប្រធានតុលាការ, ការចាត់តាំងក្រុមមេធាវីការពារក្តី,* ចុះថ្ងៃទី០៦ សីហា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៥៩-៦០ ។

[50] ICCPR, មាត្រា ១៤.៥ ។

[51] សូមអាន ICCPR, មាត្រា ១៤.៥ និង មាត្រា ១៤.៧ ។

[52] ក្រឹត្យច្បាប់, មាត្រា ២.៧ ។ *សាលក្រមរបស់តុលាការ,* ចុះថ្ងៃទី១៩ សីហា ១៩៧៩, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៥២៣ ។

*(២) ការស៊ើបសួរ និងការចោទប្រកាន់របស់ អ.វ.ត.ក - មិនហាមឃាត់ទេ*

១៧. តុលាការប្រជាជនបដិវត្តន៍ បានធ្វើការចោទប្រកាន់ និងកាត់ទោសជនត្រូវចោទពីបទប្រល័យពូជសាសន៍ ដោយអនុវត្តតាមនិយមន័យប្រល័យពូជសាសន៍មួយដែលមិនត្រូវគ្នានឹងនិយមន័យនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងច្បាប់ អ.វ.ត.ក[53] ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គ្រាន់តែបានយោងលើអនុសញ្ញានោះតែប៉ុណ្ណោះ ដោយបានប្រើពាក្យអំពើប្រល័យពូជសាសន៍នៅក្នុងន័យតាមភាសាធម្មតា និងដែលមានប្រជាប្រិយ៍ ដែលមិនមែននៅក្នុងន័យនៃការយល់អំពីច្បាប់អន្តរជាតិនោះឡើយ[54]។ ការណ៍នេះគឺច្បាស់ណាស់តាមរយៈការដាក់បញ្ចូលនូវបទឧក្រិដ្ឋនៃការជន្លៀសដោយបង្ខំ ពលកម្មដោយបង្ខំ ការបំផ្លិចបំផ្លាញទំនាក់ទំនងសង្គម អំពើទាសកម្ម ការបំផ្លិចបំផ្លាញសេដ្ឋកិច្ច ការបង្អត់អាហារ ។ល។ នៅក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍[55] ។ ជាការច្បាស់ណាស់ បទឧក្រិដ្ឋទាំងអស់នេះមិនបង្កើតបានជាទម្រង់ណាមួយជាផ្នែកនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះឡើយ ដូចដែលគេធ្លាប់ស្គាល់ទៅតាមច្បាប់អន្តរជាតិ ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា និយមន័យមិនប្រាកដប្រជាមួយនៃអំពើប្រល័យពូជសាសន៍(គ្រឿងផ្សំនៃភស្តុតាងដែលមិនយកតាមលំនាំ និងតាមការបង្ហាញភស្តុតាងដែលច្បាប់កំណត់) នៅក្នុងសវនាការជំនុំជម្រះក្តីពីមុនមួយដែលមានកំហុសមិនអាចរារាំងដល់ចោទប្រកាន់ចំពោះបទឧក្រិដ្ឋជាអន្តរជាតិ ដែលមានការកំណត់និយមន័យច្បាស់លាស់ នៅចំពោះមុខតុលាការដែលមានលក្ខណៈជាអន្តរជាតិដូចតុលាការនេះឡើយ ។ មេធាវីការពារក្តីមិនបានដាក់ជូននូវភស្តុតាងណាមួយដើម្បីបង្ហាញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង

[53] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, មាត្រា ២, ៣ ។ ច្បាប់ អ.វ.ត.ក, មាត្រា ៤ ។

[54] អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ទំព័រទី ៤៨៦ (ចែងអំពី "ការយោងទៅលើច្បាប់អន្តរជាតិក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ជាពិសេស អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ០៩ ធ្នូ ១៩៤៨, យើងយល់ឃើញថាអំពើឧក្រិដ្ឋដោយចេតនាដូចបានរៀបរាប់ខាងលើ ដែលប្រព្រឹត្តដោយបន ប៉ុល ពត - អៀង សារី បង្កើតបានជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍") ។

[55] ដីកាបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តដោយ ប៉ុល ពត - អៀង សារី, អំពើប្រល័យពូជសាសន៍នៅកម្ពុជា, ទំព័រទី ៤៦៣-៤៨ ។

សាលក្រមរបស់ PRT គឺពិតជាបានអនុវត្តទៅតាមនិយមន័យនៃអំពើប្រល័យពូជសាសន៍ ដែលស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់អន្តរជាតិនោះឡើយ ។

១៨. មេធាវីការពារក្តីមិនបានយោងនូវច្បាប់ ឬការវិភាគអង្គហេតុដើម្បីតវ៉ាថា និយមន័យនៃអំពើប្រល័យពូជសាសន៍ដែលបានចោទប្រកាន់ដោយ PRT បានដាក់បញ្ចូលក្នុងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ *ទាំងអស់* និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើ អនុសញ្ញាទីក្រុងហ្សឺណែវនោះទេ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[56] ។ តាមពិតយុត្តិសាស្ត្រអន្តរជាតិគាំទ្រចំពោះទស្សនៈមួយដែលផ្ទុយគ្នាទាំងស្រុង ។ ច្បាប់អន្តរជាតិពីដំបូងបានទទួលស្គាល់អំពើប្រល័យពូជសាសន៍ថាជាថ្នាក់ក្រោមនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[57]។ រហូតទាល់តែមានការអនុម័តអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ទើបអំពើប្រល័យពូជសាសន៍បានក្លាយទៅជាជំពូកនៃបទឧក្រិដ្ឋ *ដោយខ្លួនឯង* ដែលមាន *អំពើពិរុទ្ធ និងបំណងឧក្រិដ្ឋ* ជាក់លាក់ដោយខ្លួនឯងផ្ទាល់[58] ។

១៩. ធាតុផ្សំសត្យានុម័ត និងអត្តនោម័តនៃអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ មានភាពខុសគ្នាយ៉ាងច្រើននៅក្នុងទស្សនៈជាក់ស្តែង ។ សំរាប់ធាតុផ្សំផ្នែកសត្យានុម័តបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិមានវិសាលភាពធំធេងជាង ដោយធាតុផ្សំទាំងនេះអាចនឹងមិនរួមបញ្ចូលនៅក្នុងរង្វង់នៃអំពើប្រល័យពូជសាសន៍ទេ (ឧទាហរណ៍ដូចជាការដាក់ឲ្យជាប់ក្នុងពន្ធនាគារ ឬការធ្វើទារុណកម្មជាដើម) ។ ស្រដៀងគ្នានេះដែរ អាចនឹងថាមានអំពើប្រល័យពូជសាសន៍ (យ៉ាងហោចណាស់នៅក្រោមច្បាប់លក្ខន្តិកៈនៃ ICTY, ICTR និង ICC) ដែលជាធម្មតាមិនបានដាក់បញ្ចូលក្នុងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ (ឧទាហរណ៍ដូចជាការសម្លាប់បុគ្គលិកយោធាដែលជាប់ឃុំដែលជាសមាជិករបស់ក្រុមសាសនា ឬ ក្រុមជាតិពន្ធុណាមួយ ដោយសារមូលហេតុនៃសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមនោះ)[59] ។

---

[56] សារណា, កថាខណ្ឌទី ៩ ។

[57] សៀវភៅរបស់ Cassese, ទំព័រទី ៩៦ ។

[58] សៀវភៅរបស់ Cassese, ទំព័រទី ១០៦ ។

[59] សៀវភៅរបស់ Cassese, ទំព័រទី ១០៦ ។

២០. សំរាប់ធាតុផ្សំផ្នែកអត្តនោម័ត បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ តម្រូវឲ្យមានបំណងដើម្បីប្រព្រឹត្តិបទល្មើសជាដើមអាទិបន្ថែមពីលើចំណេះដឹងនៃការអនុវត្តន៍ ដែលមានលក្ខណៈរាលដាល និងជាប្រព័ន្ធ ដែលរួមបង្កើតបានជាបរិបទទូទៅនៃបទល្មើស ។ សំរាប់អំពើប្រល័យពូជសាសន៍ អ្វីដែលត្រូវការគឺ បំណងពិសេស ដើម្បីបំផ្លិចបំផ្លាញមួយផ្នែក ឬទាំងស្រុងនូវក្រុមជាក់លាក់ណាមួយបន្ថែមលើបំណងប្រព្រឹត្តបទល្មើសជាដើមអាទិ[60] ។ តាមការពិត តាមទស្សនៈនេះ មានពីរជំពូកមិនចុះសម្រុងនឹងគ្នាទៅវិញទៅមក ។ មានការលើកលែងតែមួយគត់គឺករណី*អំពើពិរុទ្ធ*ដែលដូចគ្នា ជាឧទាហរណ៍ករណីមនុស្សឃាតដែលនៅក្នុងករណីនេះបំណងសម្លាប់ តម្រូវឲ្យមានទាំងពីរជំពូក ។ យ៉ាងណាក៏ដោយ អំពើប្រល័យពូជសាសន៍នៅតែជាជំពូកស្វ័យយ័តដដែល សំរាប់តែអំពើប្រល័យ ពូជសាសន៍ដែលតម្រូវផងដែរនូវបំណងដើម្បីបំផ្លាញទៅលើក្រុម ។ ស្រដៀងគ្នានេះដែរ មានតែបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិប៉ុណ្ណោះដែលតម្រូវឲ្យមានចំណេះដឹងនៃការអនុវត្តន៍រាលដាល ឬ ជាប្រព័ន្ធ[61] ។

២១. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ច្បាប់អន្តរជាតិមិនទទួលស្គាល់ថាបទឧក្រិដ្ឋខ្លះ ធ្ងន់ធ្ងរជាងបទឧក្រិដ្ឋមួយផ្សេងនោះទេ ។ បទឧក្រិដ្ឋអន្តរជាតិទាំងអស់ គឺសុទ្ធតែជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ហើយគ្មានឋានានុក្រមពីភាពធ្ងន់ធ្ងររវាងបទឧក្រិដ្ឋទាំងអស់នោះឡើយ[62] ។ ពិសេសទៅទៀតតុលាការអន្តរជាតិបានពិពណ៌នាទាំងអំពើប្រល័យពូជសាសន៍ ទាំងបទក្រិដ្ឋប្រឆាំមនុស្សជាតិថាជា "បទឧក្រិដ្ឋនៃបទឧក្រិដ្ឋ"[63] និងបានកត់សំគាល់ថា ច្បាប់លក្ខន្តិកៈរបស់ពួកគេមិនបានចាត់ទុកនូវឋានៈនៃបទឧក្រិដ្ឋខុសៗគ្នាទេនៅក្នុងយុត្តាធិការរបស់ពួកគេ ឬការកាត់ទោស ដែលដាក់ទៅលើជនជាប់ចោទនៃបទឧក្រដ្ឋិទាំងនោះក៏ទេដែរ។ ប៉ុន្តែនៅក្នុងការដាក់ទោស តុលាការ

---

[60] សៀវភៅរបស់ Cassese, ទំព័រទី ១០៦ ។

[61] សៀវភៅរបស់ Cassese, ទំព័រទី ១០៦ ។

[62] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadic,* សេចក្តីសម្រេចក្នុងការវិនិច្ឆ័យលើបណ្តឹងឧទ្ធរណ៍, មតិដោយឡែករបស់ចៅក្រម Cassese, សំណុំរឿងលេខ IT-94-1-A និង IT-94-1-A*ស្ទួន,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ចុះថ្ងៃទី២៦ មករា ២០០០, កថាខណ្ឌទី ៧ [*បន្ទាប់ពីនេះទៅហៅថា៖* "សាលដីកាសម្រេចលើករណីរបស់ Tadic"] ។

[63] *រដ្ឋអាជ្ញា ទល់នឹង Furundzija,* សាលដីកា, ចុះថ្ងៃទី២១ កក្កដា ២០០០, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, សេចក្តីប្រកាសរបស់ចៅក្រម Vorah, កថាខណ្ឌទី ៥ ។

ពិតជាមានការគិតគូរអំពីកត្តាផ្សេងៗដូចជាស្ថានទម្ងន់ទោសជាដើម[64] ។ល។ ដូច្នេះគេមិនអាចប្រកែកបានទេ ដូចដែលជនត្រូវចោទរូបនេះធ្វើ ថាការចោទប្រកាន់ចំពោះអំពើប្រល័យពូជសាសន៍ពីមុន (ទោះជាមានកំហុសយ៉ាងណាក្តី) រារាំងដល់ការចោទប្រកាន់បន្ថែមណាមួយនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋធ្ងន់ធ្ងរជាអន្តរជាតិដទៃទៀត ។

## ការលើកលែងទោស និង ការអនុគ្រោះទោស មិនអាចអនុវត្តបានទេ

### សេចក្តីផ្តើម

២២. ជាសេចក្តីសំអាងផ្សេងទៀត ជនត្រូវចោទស្នើដាក់ជូនថា សូម្បីតែការកាត់ក្តីពីរដងមិនអាចយកមកអនុវត្តចំពោះ ការលើកលែងទោសនិងការអនុគ្រោះទោសដែលព្រះមហាក្សត្របានប្រទានដល់គាត់ក្នុងឆ្នាំ១៩៩៦ ដើម្បីរារាំងដល់ អ.វ.ត.ក មិនឱ្យអនុវត្តនូវយុត្តាធិការលើរូបគាត់បានដែរ ។ គាត់លើកសំអាងថា៖ ទី១) ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ គ្របដណ្តប់លើបទល្មើសនានាដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ, ទី២) ការអនុគ្រោះទោសគ្របដណ្តប់លើការកាត់ទោសឆ្នាំ១៩៧៩, និង ទី៣) ការអនុគ្រោះទោស និងការលើកលែងទោស គឺភ្ជាប់កាតព្វកិច្ចទៅលើតុលាការនេះ ។

២៣. សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធសេចក្តីសំអាងទាំងនោះចោល ។ ទីមួយ ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់មិនពាក់ព័ន្ធនឹងបទល្មើសនានាដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរទេ ហេតុដូច្នេះហើយ ការលើកលែងទោស មិនអាចអនុវត្តនៅចំពោះមុខតុលាការនេះបានទេ ។ ទីពីរ វិសាលភាពនៃការអនុគ្រោះទោសគឺមានកំរិតត្រឹម តែឱ្យរួចផុតពីការកាត់ទោសប្រហារជីវិត និងការរឹបអូសទ្រព្យសម្បត្តិតែប៉ុណ្ណោះ មិនរារាំងដល់ការស៊ើបសួរ និងការចោទប្រកាន់ទៅលើជនត្រូវចោទនៅ

---

[64] *រដ្ឋអាជ្ញា ទល់នឹង Jean Kambanda,* សាលក្រម និង ការប្រកាសទោស, សំណុំរឿងលេខ ICTR-97-23-S, អង្គជំនុំជម្រះសាលាដំបូង បន្ទប់លេខ ១, ចុះថ្ងៃទី០៤ កញ្ញា ១៩៩៨, កថាខណ្ឌទី ១២-១៣ ។

ពេលអនាគតនោះទេ ។ ទីបី សំរាប់គោលបំណងវែកញែកដោយសន្មតថា ការអនុគ្រោះទោសត្រូវបានប្រទានសំរាប់បទឧក្រិដ្ឋនានា ដែលគេបានធ្វើការចោទប្រកាន់លើរូបគាត់នោះៗ ការអនុគ្រោះទោសបែបនោះ មិនមានសុពលភាពចំពោះឧក្រិដ្ឋកម្មទាំងនោះទេ ព្រោះវាជាឧក្រិដ្ឋកម្មដែលឈរគោលការណ៍ច្បាប់អន្តរជាតិចាប់បង្ខំរដ្ឋទាំងអស់ឲ្យជាប់កាតព្វកិច្ច ដោយគ្មានការលើកលែង *(jus cogens crime)* ។ ទីបួន បើសិនការអនុគ្រោះទោស ត្រូវបានចាត់ទុកថាមានសុពលភាពក៏ដោយ ក៏តុលាការនេះគឺជា"តុលាការពិសេសដែលមានលក្ខណៈអន្តរជាតិ"មួយ មិនត្រូវបានភ្ជាប់កាតព្វកិច្ចដោយការអនុគ្រោះទោសថ្នាក់ជាតិនោះទេ ។

## អំពីច្បាប់

២៤. ការលើកលែងទោសនិងអនុគ្រោះទោស គឺជាទស្សនទានដែលខុសគ្នានៅក្រោមច្បាប់ ។ ការលើកលែងទោសចង់សំដៅទៅលើអំពើនៃអំណាចអធិបតេយ្យមួយដែលអនុញ្ញាតផ្តល់អភ័យឯកសិទ្ធិឲ្យរួចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌនានា ដល់ជនណាម្នាក់ ឬ ក្រុមណាមួយចំពោះអំពើពីអតីតកាល ។ រីឯការអនុគ្រោះទោសវិញ ត្រូវបានចេញនៅក្រោយពេលដែលតុលាការមួយរកឃើញថា ជនណាម្នាក់ត្រូវមានទោសពីបទល្មើសណាមួយ ។ ភាពខុសគ្នាដែលសំខាន់គឺថា ការលើកលែងទោសកើតមានឡើងនៅក្រោយពេលដែលតុលាការរកឃើញថា ចារីណាម្នាក់ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌនោះ គឺជាការដែលតុលាការចាប់បង្ខំឲ្យជននោះទទួលខុសត្រូវនៅក្រោយពេលបង្ហាញភស្តុតាង[65] ។ ក៏ប៉ុន្តែ ការលើកលែងទោសគឺទប់ស្កាត់តុលាការមិនឲ្យឆ្លងកាត់ដំណើរការដើម្បីស្វែងរកការពិតអំពីបទល្មើសតាមរយៈការជំនុំជម្រះក្តីនោះទេ។

២៥. ក៏ប៉ុន្តែសកម្មភាពទាំងពីរដែលមានលក្ខណៈខុសផ្សេងពីគ្នានេះ គឺមានប្រសិទ្ធិភាពដំណើរការតាមផ្លូវច្បាប់បានដូចគ្នាក្នុងរបៀបមួយដ៏សំខាន់ ។ ទាំងពីរនេះគឺសុទ្ធតែជារបាំងរារាំង

---

[65] Diane Orenlichter, *ដំណើររឿងដោះស្រាយក្តី៖ ករណីយកិច្ចក្នុងការជំនុំជម្រះក្តីអំពីការរំលោភលើសិទ្ធិមនុស្សនៃរបបមុន, 100 Yale L J 2537, 2604 (1991)* ។

មិនឱ្យជនណាមួយរួចផុតពីការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌ ឬពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី[66] ។ ហេតុដូចនេះ ការលើកលែងទោស និងការអនុគ្រោះទោស នៅពេលខ្លះលើកឡើងយោងគ្នាវិញទៅមកក្នុងលក្ខណៈជាការផ្លាស់ប្តូរគ្នា[67] ។

២៦. យុត្តិសាស្ត្រ និងទម្លាប់អនុវត្តសិទ្ធិមនុស្សអន្តរជាតិ គូសបញ្ជាក់អំពីជំហរដែលថា ចំពោះបទរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចជានៅក្នុងករណីនេះជាដើម ទាំងការលើកលែងទោស ឬទាំងការអនុគ្រោះទោស គឺសុទ្ធតែមិនត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នោះទេ[68] ។ កិច្ចព្រមព្រៀងដើម្បីបង្កើតតុលាការនេះឡើង គឺទាមទារឱ្យមានការលើកស្ទួយបទដ្ឋានអន្តរជាតិ[69] ។ បទដ្ឋានអន្តរជាតិបែបដូច្នេះ ចាំបាច់ត្រូវមានលំហូរចេញមកពីច្បាប់ និងនីតិវិធីដែលបានបង្កើតឡើងនៅតាមតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការដែលបានធ្វើឱ្យមានលក្ខណៈជាអន្តរជាតិនានា ដែលតុលាការទាំងនោះផ្ទាល់ ធ្លាប់បានធ្វើការដោះស្រាយលើឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងទៅលើមហាជន ស្រដៀងគ្នានឹងឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងដែលកំពុងត្រូវបានធ្វើការជំនុំជម្រះក្តីនៅចំពោះមុខ អ.វ.ត.ក ដូច្នោះដែរ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមឱ្យ អ.ប.ជ លើកស្ទួយ និងអនុវត្តនូវគោលការណ៍នានា ដែលត្រូវបានបង្កើតឡើងដោយយុត្តិសាស្ត្ររបស់តុលាការបែបតាំងនោះ ។

---

[66] វចនានុក្រម Black Law, បោះពុម្ពលើកទី ៨, ការលើកលែងទោស ។

[67] *រដ្ឋអាជ្ញា ទល់នឹង Kallon និង Kamara,* សេចក្តីសម្រេចលើការតវ៉ាចំពោះយុត្តាធិការ ។ កិច្ចព្រមព្រៀងលើកលែងទោសនៃទីក្រុងឡូម, សំណុំ រឿងលេខ SCSL-2004-15-AR72(E) និង SCSL-2004-16-AR72(E), ចុះថ្ងៃទី១៣ មីនា ២០០៤, កថាខណ្ឌទី ២១ [*បន្ទាប់ពីនេះទៅហៅថា៖* "សេចក្តីសម្រេចលើករណីរបស់ Kallon"] ។

[68] Leila Sadat, *ការនិរទេស, ការលើកលែងទោស និង ច្បាប់អន្តរជាតិ,* 81 Notre Dame L R 955, 957 (2006) ។

[69] កិច្ចព្រមព្រៀង, មាត្រា ១២ ។

## *យុត្តិសាស្ត្រអន្តរជាតិ*

២៧. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មដែលគោលការណ៍ច្បាប់អន្តរជាតិបង្ខំឱ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (jus cogens crime)[70] ។ នេះគឺជានិយាមនៃច្បាប់អន្តរជាតិដែលមិនអាចបដិសេធបាន (peremptory norm) ដែលថាការប្រមាថមិនត្រូវបានអនុញ្ញាតឱ្យមានបានឡើយ[71] ។ ក្នុង*រឿងក្តីរបស់ Barcelona Traction* ក្នុងឆ្នាំ ១៩៧០ តុលាការយុត្តិធម៌អន្តរជាតិ ("ICJ") បានសម្រេចថា រដ្ឋទាំងអស់ត្រូវតែពង្រឹងការអនុវត្តន៍ដើម្បីហាមឃាត់ប្រឆាំងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដើម្បីធ្វើជាកាតព្វកិច្ចចាប់បង្ខំ (Obligation *erga omnes*)[72] ។ តាមន័យបង្កាប់ គឺរដ្ឋទាំងអស់ត្រូវមានភារកិច្ចទូទៅមួយ ដើម្បីចាត់វិធានការណ៍បង្ការ និង *ផ្តន្ទាទោស* ចំពោះអំពើប្រល័យពូជសាសន៍[73] ។

២៨. តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") បានទទួលស្គាល់នូវ "និយាមអន្តរជាតិមួយដែលកំពុងចេញជារូបរាងច្បាស់លាស់ ដែលរដ្ឋាភិបាលមិនអាចអនុញ្ញាតផ្តល់នូវការលើកលែងទោសណាមួយចំពោះបទល្មើស ស្តីពីការរំលោភបំពានធ្ងន់ធ្ងរផ្សេងៗ លើច្បាប់មនុស្សធម៌អន្តរជាតិបានទេ"[74] ។ ស្របតាមនេះ រដ្ឋាភិបាលនេះបានសម្រេចថាខ្លួនអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីកុំឱ្យដាក់ទម្ងន់ទៅលើការលើកលែងទោសណាមួយ ដែលត្រូវបានអនុញ្ញាតផ្តល់ឱ្យកន្លងមក ដែលមានលក្ខណៈផ្ទុយទៅនឹងគោលការណ៍ដែលកំពុងតែវិវឌ្ឍន៍ទាំងឡាយនៃច្បាប់អន្តរជាតិ និងទៅនឹង"កាតព្វកិច្ចផ្សេងៗក្រោមសន្ធិសញ្ញា និងអនុសញ្ញា

---

[70] *រដ្ឋអាជ្ញា ទល់នឹង Rutaganda,* សាលក្រម និង ការប្រកាសទោស, សំណុំរឿងលេខ ICTR-96-3-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR, ចុះថ្ងៃទី០៦ ធ្នូ ១៩៩៩, កថាខណ្ឌទី ៤៥១ ។ *រដ្ឋអាជ្ញា ទល់នឹង Servashago,* ការប្រកាសទោស, សំណុំរឿងលេខ ICTR-98-39-T, ចុះថ្ងៃទី០២ កុម្ភៈ ១៩៩៩, កថាខណ្ឌទី ១៥ ។

[71] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា, មាត្រា ៥៣ ។

[72] *Barcelona Traction, Light and Power Co. Ltd,* (ប្រទេសបែលហ្ស៊ិក ទល់នឹង ប្រទេសអេស្ប៉ាញ) (ឆ្នាំ១៩៧០) ICJ, ចុះថ្ងៃទី ០៥ កុម្ភៈ ១៩៧០, កថាខណ្ឌទី ៣៤ ។

[73] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, មាត្រា ១ ។ (បញ្ជាក់ន័យបន្ថែមដោយ *អក្សរទ្រេត*) ។

[74] សាលដីកាសម្រេចលើករណីរបស់ Kallon, កថាខណ្ឌទី ៨២ ។

នានាមួយចំនួនដែលមានគោលបំណងដើម្បីការពារមនុស្សជាតិ”[75] ។ រដ្ឋាភិបាលនេះបានសម្រេចថា នៅក្នុងច្បាប់អន្តរជាតិគឺរដ្ឋនានាជាអ្នកត្រូវមានភារកិច្ចក្នុងការកាត់សេចក្តីចំពោះរាល់បទល្មើសទាំងឡាយ ដែលការហាមឃាត់របស់ខ្លួនបានឈានទៅដល់ឋានៈ (កំរិត) ជាគោលការណ៍ច្បាប់អន្តរជាតិបង្ខំឱ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (Status of *jus cogens* )[76] ។ តុលាការពិសេសនោះបានលើកសំអាងទៅលើរបាយការណ៍មួយរបស់អង្គការសហប្រជាជាតិដែលបាននិយាយថា ការលើកលែងទោសទាំងឡាយណាដែលខុសច្បាប់ គឺមិនអាចអនុញ្ញាតឱ្យបានទេចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងឡាយដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើរំលោភបំពានធ្ងន់ធ្ងរដទៃទៀតលើច្បាប់មនុស្សធម៌អន្តរជាតិ[77] ។

២៩. នៅក្នុងរឿងក្តីរបស់ *Furundzija* តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) មិនគ្រាន់តែហាមឃាត់លើការធ្វើទារុណកម្ម ដែលគោលការណ៍ច្បាប់អន្តរជាតិបង្ខំឱ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (jus cogens crime) ប៉ុណ្ណោះទេ ក៏ប៉ុន្តែថា ការលើកលែងទោសណាមួយក៏ដោយចំពោះឧក្រិដ្ឋកម្មនោះ គឺជាការមិនស្របជាមួយច្បាប់អន្តរជាតិទៅហើយ[78] ។ ច្បាប់លក្ខន្តិកៈនិងវិធាននៃតុលាការ ICTY និង ICTR បានគិតគូរពិចារណាលើការអនុគ្រោះទោសតែក្នុងករណីណាដែលទណ្ឌិតបានអនុវត្តទោសដែលត្រូវបានកាត់ឱ្យជាប់របស់ខ្លួនបានមួយភាគ[79] រួចហើយៗនិងដោយស្ថិតនៅក្រោម

---

[75] សាលដីកាសម្រេចលើករណីរបស់ Kallon, កថាខណ្ឌទី ៨២, ៨៤។

[76] *រដ្ឋអាជ្ញា ទល់នឹង Augustine Gbao,* សេចក្តីសម្រេចលើញត្តិបឋមស្នើសុំបញ្ឈប់សុពលភាពនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលនៃប្រទេសសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេស, សំណុំរឿងលេខ SCSL-2004-15-PT, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL, ចុះថ្ងៃទី២៥ ឧសភា ២០០៤, កថាខណ្ឌទី ១០ [*បន្ទាប់ពីនេះទៅហៅថា៖* “សាលដីកាសម្រេចលើករណីរបស់ Gbao”] ។

[77] សាលដីកាសម្រេចលើករណីរបស់ Gbao, កថាខណ្ឌទី ១០ ។

[78] *រដ្ឋអាជ្ញា ទល់នឹង Furundzija,* សាលក្រម, សំណុំរឿងលេខ IT-95-17/1-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី ១០ ធ្នូ ១៩៩៨, កថាខណ្ឌទី ១៥៣, ១៥៦ ។

[79] លក្ខន្តិកៈសម្រាប់ ICTY, មាត្រា ២៨ ។ លក្ខន្តិកៈសម្រាប់ ICTR, មាត្រា ២៧ ។

លក្ខណ្ឌមួយចំនួនតែប៉ុណ្ណោះ[80] ។ ការលើកលែងទោសណាមួយ គឺមុខជានឹងមានវិសមិតភាពជាមួយនិងទម្លាប់អនុវត្តនេះ ។

៣០. ប្រព័ន្ធសិទ្ធិមនុស្សសម្រាប់អន្តរទ្វីបអាមេរិកកាំង ក៏បានសម្រេចស្របគ្នាដដែលៗថាក្រឹត្យស្តីពីការលើកលែងទោស គឺវាមានវិសមិតភាពជាមួយនឹងកាតព្វកិច្ចទាំងឡាយរបស់រដ្ឋណាមួយ ដែលជាអ្នកត្រូវផ្តល់នូវការដាក់ទណ្ឌកម្មយ៉ាងសមស្របចំពោះជនទាំងឡាយ ដែលត្រូវទទួលខុសត្រូវចំពោះបទរំលោភសិទ្ធិមនុស្សផ្សេងៗ[81] ។ តាមសេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សសម្រាប់អន្តរទ្វីបអាមេរិកកាំងថា ការអនុញ្ញាតផ្តល់នូវការលើកលែងទោស ឬការអនុគ្រោះទោសណាមួយចំពោះការរំលោភលើសិទ្ធិមនុស្ស គឺជាការបង្កើតឱ្យមាននូវការរំលោភបំពានចំពោះកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋនោះ[82] ។

## *យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ*

៣១. យន្តការសិទ្ធិមនុស្សនានា បានថ្លែងឡើងវិញជាថ្មីដដែលៗថា ការលើកលែងទោសក្នុងស្រុកដោយប្រទានចោលនូវការកាត់សេចក្តីពីបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរផ្សេងៗនោះ គឺមានវិសមិតភាពជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋទាំងឡាយជាភាគីទាំងនោះ ។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ (“HRC”) បានសង្កត់ធ្ងន់ថា ការលើកលែងទោសទាំងឡាយបែបនោះគឺជាការចូលរួមចំណែកក្នុងការបង្កើតឡើងនូវបរិយាកាសនៃនិទណ្ឌភាពមួយដល់ជនដៃ

---

[80] លក្ខន្តិកៈនេះអនុញ្ញាតឱ្យមានការកាត់បន្ថយទោសតែនៅក្នុងករណី ដែលប្រធានសាលាជំនុំជម្រះក្តីធ្វើការកំណត់ឱ្យប៉ុណ្ណោះ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រម និងថា ការកាត់បន្ថយនេះត្រូវតែផ្អែកលើ “ប្រយោជន៍ដល់យុត្តិធម៌ និងគោលការណ៍ទូទៅនៃច្បាប់” ។ វិធានស្តីពីនីតិវិធី និង ភស្តុតាងនៃសាលាជំនុំជម្រះក្តីទាំងនេះចែងថា “នៅក្នុងការកំណត់នេះ ប្រធានត្រូវគិតគូរក្នុងចំណោមកត្តាផ្សេង “ អំពីស្ថានទម្ងន់នៃបទឧក្រិដ្ឋមួយ ឬ ច្រើន ដែលអ្នកទោសត្រូវបានកាត់ឱ្យជាប់ទោស” ។

[81] តុលាការអន្តរទ្វីបអាមេរិកកាំងសម្រាប់សិទ្ធិមនុស្ស, *ករណីរបស់ Velásquez Rodriguez,* សេចក្តីសម្រេច ចុះខែកក្កដា ១៩៨៨, សេរី C, លេខ ៤, កថាខណ្ឌទី ១៧៤ និង *ករណីរបស់ Godínez Cruz,* សេចក្តីសម្រេច ចុះថ្ងៃទី២០ មករា ១៩៨៩, សេរី C, លេខ ៥, កថាខណ្ឌទី ១៨៤ ។

[82] តុលាការអន្តរទ្វីបអាមេរិកកាំងសម្រាប់សិទ្ធិមនុស្ស, សេរី C៖ សេចក្តីសម្រេច និង សាលក្រម, លេខ ៤, *Caso Velázquez Rodriguez,* សាលក្រមចុះថ្ងៃទី២៩ កក្កដា ១៩៨៨ កថាខណ្ឌទី ១៧៦ ។

ដល់ដែលរំលោភសិទ្ធិមនុស្សនានា និងជាការធ្វើឱ្យខូចដល់ការខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យកើតមានឡើងវិញនូវការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ[83] ។ គណៈកម្មាធិការនេះបានពិពណ៌នាថា ការលើកលែងទោសចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិថា "ជាទូទៅគឺមានវិសមិតភាពជាមួយនឹងកាតព្វកិច្ចរបស់រដ្ឋនានាក្នុងការស៊ើបអង្កេតទៅលើអំពើទាំងឡាយបែបនេះ ដើម្បីនឹងធានារ៉ាប់រងនូវសេរីភាពរួចផុតពីអំពើទាំងនេះដែលឋិតនៅក្នុងយុត្តាធិការរបស់ខ្លួន ។ និងដើម្បីធានាថា អំពើទាំងនេះនឹងមិនមានកើតឡើងជាថ្មីទៀតទេនៅក្នុងពេលអនាគត"[84] ។ គណៈកម្មាធិការនេះបានរកឃើញករណីស្រដៀងៗគ្នានេះ មកពីប្រទេសឈីលី[85] ប្រទេសប៉េរូ[86] ប្រទេសលីបង់[87] ប្រទេសអែលសាវ៉ាឌ័រ[88] ប្រទេសហៃទី[89] និង ប្រទេសអ៊ុយរុយហ្គាយ[90] ។ ការរកឃើញនានារបស់គណៈកម្មាធិការ អ.ស.ប ប្រឆាំងនឹងការធ្វើទារុណកម្ម ("CAT") ក៏គាំទ្រចំពោះទស្សនៈខាងលើនេះដែរ[91] ។

[83] គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ និង អង្គការលើកលែងទោសអន្តរជាតិ, *សារណាច្បាប់ស្តីពីវិសមិតភាពនៃក្រឹត្យច្បាប់របស់ប្រទេសឈីលី លេខ ២១៩១ ឆ្នាំ១៩៧៨ ជាមួយនឹង ច្បាប់អន្តរជាតិ,* ថ្ងៃទី១៥ ធ្នូ ២០០០, ទំព័រទី ៩ *អាចរកបានតាម៖* http://www.icj.org/IMG/pdf/Chile-eng.pdf [*បន្ទាប់ពីនេះទៅហៅថា៖* "គណៈកម្មការក្រុមអ្នកច្បាប់អន្តរជាតិ"] ។

[84] យោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ២០ (៤៤) ស្តីពី ICCPR មាត្រា ៧, ត្រង់កថាខណ្ឌទី ១៥, *អាចរកបានតាម៖* http://www.unhchr.ch/tbs/doc.nsf/(Symbol)/6924291970754969c12563ed004c8ae5?Opendocument ។

[85] សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ ស្តីពីប្រទេសឈីលី ចុះថ្ងៃទី៣០ មីនា ១៩៩៩, ឯកសារអង្គការសហប្រជាជាតិ លេខ CCPR/C/79/Add.104, កថាខណ្ឌទី ៧ ។

[86] ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/79/Add.67, កថាខណ្ឌទី ៩ ។ *សូមមើលផងដែរ៖* សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ ស្តីពីប្រទេសប៉េរូ, នៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/CO/70/PER, កថាខណ្ឌទី ៩ ។

[87] ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/79/Add.78, កថាខណ្ឌទី ១២ ។

[88] ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/79/Add.34, កថាខណ្ឌទី ៧ ។

[89] ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/50/40, កថាខណ្ឌទី ២២៤-២៤១ ។

[90] ឯកសាររបស់អង្គការសហប្រជាជាតិ លេខ CCPR/C/79/Add.19, កថាខណ្ឌទី ៧ និង ១១ ។

[91] គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើទារុណកម្ម, សេចក្តីសម្រេចស្តីពីការប្រាស្រ័យទាក់ទងលេខ ១/១៩៨៨, លេខ ២/១៩៨៨ និង លេខ ៣/១៩៨៨, ចុះថ្ងៃទី២៣ វិច្ឆិកា ១៩៨៩, កថាខណ្ឌទី ៧.២ ។

## ទម្លាប់អនុវត្តរបស់រដ្ឋនានា

៣២. ទម្លាប់អនុវត្តរបស់រដ្ឋនានាក៏គាំទ្រចំពោះនិយាមដែលកំពុងតែលេចចេញជារូបរាងយ៉ាងច្បាស់លាស់នេះដែរ។ មានតុលាការជាតិជាច្រើនបានចាត់ទុកជាមោឃៈនូវការលើកលែងទោសនៅក្នុងស្រុកជាច្រើនករណីដែលត្រូវបានអនុញ្ញាតផ្តល់ទៅឱ្យមេដឹកនាំយោធា និងនយោបាយនានាដែលជាប់សង្ស័យពីបទឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗដែលរំលោភទៅលើច្បាប់អន្តរជាតិ[92] ។ តុលាការទាំងនោះធ្វើការសម្រេចដូច្នេះគឺ ដោយផ្អែកទៅលើឧត្តមភាពនៃច្បាប់អន្តរជាតិដែលស្ថិតនៅក្នុងឋានានុក្រមនៃរដ្ឋធម្មនុញ្ញក្នុងស្រុក[93] វិសមិតភាពនៃច្បាប់ក្នុងស្រុកជាមួយនឹងសន្ធិសញ្ញាអន្តរជាតិនានា និងទៅលើអង្គហេតុដែលឧក្រិដ្ឋកម្មជាប់ទាក់ទងនោះវាការរំលោភទៅលើនិយាមអន្តរជាតិ ដែលបង្ខំឱ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (*jus cogens* norm)[94]។ ហើយក៏មាននិន្នាការដែលកំពុងតែរីកធំធាត់ឡើងផងដែរដែលឈានឆ្ពោះទៅរកការហាមឃាត់ការផ្តល់ការលើកលែងទោសផ្សេងៗ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ជាតិនានា[95] ។ រដ្ឋទាំងឡាយ ដែលផ្តល់ការលើកលែងទោសក៏កំពុងតែបង្កើនផងដែរនូវច្រានចោលចេញពីវង្វង់សមត្ថកិច្ចរបស់ខ្លួនចំពោះជនទាំងឡាយណា ដែលជាប់ពិរុទ្ធអំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗដូចជា ការធ្វើទារុណកម្ម ការបាត់ខ្លួនដោយបង្ខំ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[96] ។

---

[92] Cassel, Douglass, *ភាពបំពេញបន្ថែម, ការលើកលែងទោស និង ទម្រង់យុត្តិធម៌ផ្សេងៗទៀត៖ គោលការណ៍ណែនាំមួយចំនួនសម្រាប់ធ្វើការបកស្រាយនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* 3 J. Int`l Crim. Just. 695, 720 (ឆ្នាំ ២០០៥) [*បន្ទាប់ពីនេះទៅហៅថា៖* "អត្ថបទរបស់ Cassel"] ។ Fannie Lafontaine, *គ្មានការលើកលែងទោស ឬ គ្មានអាជ្ញាយុកាល ចំពោះបទបាត់ខ្លួនដោយបង្ខំទេ៖ ករណីរបស់ Sandoval នៅ ចំពោះមុខតុលាការកំពូលនៃប្រទេសឈីលី* 3 J. Int"l Crim. Just. 469, ត្រង់ទំព័រទី ៤៧១ [*បន្ទាប់ពីនេះទៅហៅថា៖* "អត្ថបទរបស់ Lafontaine"] ។

[93] អត្ថបទរបស់ Lafontaine, ទំព័រទី ៤៧៥ ។

[94] អត្ថបទរបស់ Cassel, ទំព័រទី ៧២០ ។

[95] អត្ថបទរបស់ Cassel, ទំព័រទី ៧២០ ។

[96] អត្ថបទរបស់ Cassel, កំណត់សម្គាល់ជើងទំព័រទី ២៥ ។ (ច្បាប់លើកលែងទោសមួយរបស់ប្រទេសកូឡុំប៊ី ឆ្នាំ១៩៨២ បានដកចេញនូវជនទាំងឡាយដែលមានពិរុទ្ធភាពពីបទ៖ ការធ្វើទារុណកម្ម ការបាត់ខ្លួនដោយបង្ខំ និង ការសម្លាប់ជីវិត ។ មានបញ្ញត្តិមួយនៃរដ្ឋធម្មនុញ្ញរបស់ប្រទេសប៉័រទុយហ្កាល់ បានដកចេញនូវការលើកលែងទោសរបស់មន្ត្រីជាន់ខ្ពស់ណាម្នាក់នៃកងកម្លាំងសន្តិសុខ ដែលត្រូវបានចោទប្រកាន់ពីបទបានបញ្ជាឱ្យធ្វើទារុណកម្ម ។ ការផ្តល់ការលើកលែងទោសមួយត្រូវបានផ្តល់ឱ្យយុទ្ធជនអាល់បានីនានានៅទីក្រុងម៉ាសេដូនី

00189200

E22/I/32

## សេចក្ដីសំអាង

### *(១) ច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ មិនមានការទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយរបស់ អ.វ.ត.ក ទេ*

៣៣. ការលើកលែងទោសដែលត្រូវបានផ្ដល់ទៅឱ្យជនត្រូវចោទរួចផុតពីការកាត់ទោសនៅក្នុងពេលអនាគតក្រោមច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់គឺ មិនអាចអនុវត្តបានទេនៅចំពោះមុខតុលាការនេះ។ ច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់គឺមានគម្រោងសម្រាប់អនាគតដើម្បីធ្វើការផ្ដន្ទាទោសជាបទព្រហ្មទណ្ឌ ចំពោះសមាជិករបស់ខ្មែរក្រហមចាប់ពីរយៈពេល៦ខែក្រោយពេលអនុម័តច្បាប់នេះ[97]។ ច្បាប់នេះបានលើកឡើងសំដៅទៅលើជនទាំងឡាយ "ដែលប្រព្រឹត្ត"[98] (មិនបានចែងថា *ជនទាំងឡាយណាដែលបានប្រព្រឹត្ត* នោះទេ) នូវសកម្មភាពដែលតស៊ូប្រឆាំងនឹងរដ្ឋ[99] ។ រីឯច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក វិញ បានចែងអនុញ្ញាតផ្ដល់យុត្តាធិការអំពីពេលវេលាដល់តុលាការនេះដោយកំណត់យ៉ាងម៉ឺងម៉ាត់យកតែឧក្រិដ្ឋកម្មទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងចន្លោះ ពេលពីថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ និងថ្ងៃទី ៦ មករា ឆ្នាំ១៩៧៩[100] តែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះ បទល្មើសទាំងឡាយ ដែលអាចចោទប្រកាន់បានក្រោមច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ គឺឋិតនៅក្រៅពីវង្វង់យុត្តាធិការអំពីពេលវេលារបស់តុលាការនេះ ។

៣៤. កិច្ចព្រមព្រៀងក៏បានចែងបញ្ជាក់យ៉ាងច្បាស់ដែរថា ការអនុគ្រោះទោសរបស់ជនត្រូវចោទជាប់ជំពាក់តែទៅនឹងការផ្ដន្ទាទោសក្នុងឆ្នាំ ១៩៧៩ ប៉ុណ្ណោះ ហើយមិនទាក់ទងទៅនឹងច្បាប់

---

ដោយដកចេញនូវបទ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទារុណកម្ម និង ការរំលោភលើច្បាប់សិទ្ធិមនុស្សអន្តរជាតិយ៉ាងធ្ងន់ធ្ងរ) ។

[97] ច្បាប់ស្ដីពីការដាក់ឱ្យនៅក្រៅច្បាប់, មាត្រា ២, ៥ ។

[98] ច្បាប់ស្ដីពីការដាក់ឱ្យនៅក្រៅច្បាប់, មាត្រា ៣ ។

[99] ច្បាប់ស្ដីពីការដាក់ឱ្យនៅក្រៅច្បាប់, មាត្រា ៤ ។

[100] ច្បាប់ អ.វ.ត.ក, មាត្រា ១ ។ កិច្ចព្រមព្រៀង, មាត្រា ១ ។

ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់នោះទេ ។ កិច្ចព្រមព្រៀងនេះបានចែងថា៖ *"មានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី ១៤ កញ្ញា ១៩៩៦ ពេលដែលការលើកលែងទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ ដែលត្រូវបានផ្តន្ទាទោសនៅ ឆ្នាំ១៩៧៩ ពីបទប្រល័យពូជសាសន៍"*[101] ។

### *(២) វិសាលភាពនៃការអនុគ្រោះទោស និងការលើកលែងទោសត្រូវបានកម្រិត*

៣៥. ផ្ទុយពីការអះអាងរបស់គាត់ ជាសំខាន់បំផុតជនត្រូវចោទមិនបានទទួលនូវការអនុគ្រោះទោសឲ្យរួចផុតពីការផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ[102] ។ ភាសាដែលប្រើនៅក្នុងការអនុគ្រោះទោសគឺមានលក្ខណៈចង្អៀត និងជាក់លាក់[103]។ ការអនុគ្រោះទោសនោះមានការកំរិតកំណត់ចំពោះវិសាលភាព ដែលផ្តល់ការអនុគ្រោះទោសដល់ជនត្រូវចោទតែចំពោះ "ទោសប្រហារជីវិតបង់ និងការរឹបអូសទ្រព្យសម្បត្តិ"តែប៉ុណ្ណោះ[104] ។ ក្នុងនោះមិនបានលើកឡើងអំពីការប្រព្រឹត្ត ឬបទល្មើសណាមួយដែលគាត់ត្រូវបានគេផ្តល់ការអនុគ្រោះទោសទេ ហើយហេតុដូចនេះគឺមិនបានផ្តល់ការអនុគ្រោះទោសដល់គាត់ចំពោះ "បទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍"នោះឡើយ ។ ហើយចំពោះបទល្មើសផ្សេងៗទៀតដែលគាត់អាចនឹងធ្លាប់បានប្រព្រឹត្តនៅក្នុងចន្លោះពេលចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" ក៏គាត់មិនត្រូវបានទទួលការ

[101] កិច្ចព្រមព្រៀង, មាត្រា ១១.២ (បញ្ជាក់ន័យបន្ថែមដោយ *អក្សរទ្រេត*) ។

[102] សារណា, កថាខណ្ឌទី ១០ ។

[103] ក្នុងការវាយតម្លៃទៅលើវិសាលភាពនៃការអនុគ្រោះទោសរបស់ជនត្រូវចោទ វាមានប្រយោជន៍ច្រើនក្នុងការប្រៀបធៀបអំពីភាសាដ៏ចង្អៀតចង្អល់នៃការអនុគ្រោះទោសរបស់គាត់ ជាមួយនឹងភាសាដ៏ទូលំទូលាយយ៉ាងខ្លាំងនៃការអនុគ្រោះទោសដែលបានផ្តល់ដោយរដ្ឋាភិបាលនៃប្រទេសសៀរ៉ាឡេអូន ដើម្បីទទួលបាននូវការបញ្ឈប់ជម្លោះនៅក្នុងប្រទេសនេះ ។ សេចក្តីសម្រេចលើករណីរបស់ Kallon, កថាខណ្ឌទី ៧ ។

[104] ភាសាដែលពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀងទាក់ទងនឹងការអនុគ្រោះទោស អៀង សារី គឺស៊ីសង្វាក់គ្នាជាមួយនឹងការបកស្រាយនេះ ។ មាត្រា ១១.២ នៃកិច្ចព្រមព្រៀង ដែលសំដៅទៅលើការអនុគ្រោះទោសនេះរៀបរាប់ថា "ការអនុគ្រោះទោសត្រូវបានផ្តល់ជូនសំរាប់មនុស្សតែម្នាក់គត់ *ដែលទាក់ទិនទៅនឹង* ការកាត់ទោសលើបទចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍" ។ ការអនុគ្រោះទោសនេះ *មិន*បានរៀបរាប់ថាជា ការអនុគ្រោះទោសមួយ "សំរាប់" ឬ "នៃ" ការកាត់ទោសលើបទចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍នោះទេ ។ ភាសាដែលកាន់តែមានលក្ខណៈទូទៅទៀតនោះ គឺពាក្យថា-"ទាក់ទិនទៅនឹង"-ដែលបំរើចំពោះតែការកំណត់ទៅលើការអនុគ្រោះទោសមួយដូចដែលមានចែង នៅក្នុងមាត្រា ១១ តែប៉ុណ្ណោះ ។

អនុគ្រោះទោសដែរ ។ អាស្រ័យហេតុនេះ ការអនុគ្រោះទោសនោះគឺគ្មានអ្វីដើម្បីរារាំងចំពោះការកាត់ទោសរូបគាត់អំពីឧក្រិដ្ឋកម្មណាមួយ ដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការនេះឡើយ ។

៣៦. ក្នុងការបកស្រាយអំពីការអនុគ្រោះទោសតាមរបៀបដូចនេះ និងការកម្រិតកំណត់ចំពោះការលើកលែងទោសនេះទៅតាមភាសាពិតប្រាកដរបស់វា គឺជាការផ្តល់នូវការទទួលស្គាល់យ៉ាងពិតប្រាកដចំពោះវិសាលភាពរបស់វា ដែលទន្ទឹមគ្នានេះក៏ផ្តល់កិត្តិយសដល់កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិរបស់ប្រទេសកម្ពុជាផងដែរ ។ ការបកស្រាយនេះរំលេចឱ្យឃើញយ៉ាងប្រសើរបំផុតផងដែរអំពីចេតនារបស់រដ្ឋាភិបាលកម្ពុជានៅក្នុងពេលផ្តល់ការអនុគ្រោះទោស ។ ផ្ទុយពីការពោលអះអាងរបស់ជនត្រូវចោទស្តីពីចេតនារបស់រដ្ឋាភិបាលកម្ពុជា[105] នៅក្នុងពេលជាទន្ទឹមគ្នានោះដែរលោកនាយករដ្ឋមន្ត្រីបានចង្អុលបង្ហាញថា វិសាលភាពនៃការអនុគ្រោះទោសត្រូវបានកម្រិតដោយប្រុងប្រយ័ត្ន ដើម្បីទុកចន្លោះសម្រាប់ធ្វើការកាត់ទោសនៅពេលអនាគត[106] ។

៣៧. លោក Thomas Hammarberg តំណាងពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០០ តែងបានជួបជាញឹកញាប់ជាមួយលោកនាយករដ្ឋមន្ត្រីនិងបានថ្លែងថា ៖ " *[លោកនាយករដ្ឋមន្ត្រី] បានពន្យល់ខ្ញុំថា គោលបំណងនៃការលើកលែងទោសគឺ ដើម្បីលើកទឹកចិត្តឱ្យមកចុះចូលកាន់តែច្រើនថែមទៀត ។ ក្រឹត្យស្តីពីការលើកលែងទោសចំពោះ អៀង សារី ក៏ត្រូវបានបង្កើតឡើងដោយចេតនាដើម្បីការពារកុំឱ្យ*

---

105 សារណា, កថាខណ្ឌទី ៣៤ ។

106 *Tom Fawthrop និង Helen Jarvis*, "ការគេចចេញពីអំពើប្រល័យពូជសាសន៍"? (Getting Away With Genocide?) យុត្តិធម៌ដែលពិបាកយល់ និង សាលាក្តីខ្មែរក្រហម, ឆ្នាំ២០០៤ ទំព័រទី ១៧២ (បានដកស្រង់ពីរបាយការណ៍នៅក្នុងកាសែត *Phnom Penh Post* នូវប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រីថា៖ "បើអ្នកធ្វើការសិក្សាអំពីពាក្យនៅក្នុងព្រះរាជក្រឹត្យ នោះអ្នកនឹងឃើញថាគឺនៅតែមានលទ្ធភាពដើម្បីធ្វើការកាត់ទោសអំពីឧក្រិដ្ឋកម្មដែល អៀង សារី បានប្រព្រឹត្ត ។ យើងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅនឹងពាក្យអនុគ្រោះទោស... គឺវាមិនមានអ្វីនៅក្នុងពាក្យនោះដែលរារាំង ដល់ការចោទប្រកាន់លើ អៀង សារី នៅចំពោះមុខតុលាការមួយដែលនឹងអាចបង្កើតឡើងនៅពេលខាងមុខនេះទេ") ។

*តុលាការឆ្នាំ១៩៧៩ ផ្ដន្ទាទោសចំពោះរូបគាត់តែប៉ុណ្ណោះ និងដើម្បីអាចមានលទ្ធភាពក្នុងការកាត់ទោសអំពីបទបានរំលោភបំពានលើច្បាប់ឆ្នាំ១៩៩៤ ដែលហាមឃាត់ចំពោះសកម្មភាពរបស់ខ្មែរក្រហម*"[107] ។

### *(៣) ការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលគោលការណ៍ច្បាប់អន្តរជាតិបង្ខំឲ្យ រដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (jus cogens crime) គឺមិនអាចអនុញ្ញាតទេ*

៣៨. ដូចបានលើកឡើងខាងលើ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺជា ឧក្រិដ្ឋកម្មទាំងឡាយណាដែលគោលការណ៍ច្បាប់អន្តរជាតិបង្ខំឲ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (*jus cogens* crime) ។ ការអនុគ្រោះទោសណាមួយចំពោះឧក្រិដ្ឋកម្មអន្តរជាតិគឺមិនអាចលើកលែងទោសឲ្យបានឡើយ ។ ហេតុដូចនេះ ការអនុគ្រោះទោសដែលបានប្រទានដោយព្រះមហាក្សត្រដល់ការផ្ដន្ទាទោសឆ្នាំ១៩៧៩ របស់ជនត្រូវចោទរូបនេះ គឺមិនមានសុពលភាពទេ ។ ការផ្ដល់ការអនុគ្រោះទោសណាមួយចំពោះឧក្រិដ្ឋកម្មដែលគោលការណ៍ច្បាប់អន្តរជាតិបង្ខំឲ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (*jus cogens* crime) ដែលទណ្ឌិតមិនបានអនុវត្តទោសផងនោះ ក៏រំលោភផងដែរទៅលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការផ្ដន្ទាទោសជនទាំងឡាយដែលត្រូវទទួលខុសត្រូវចំពោះឧក្រិកម្មផ្សេងៗ ដែលថិតក្រោមអនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ អនុសញ្ញានោះបានចែងថា ជនទាំងឡាយណាដែលប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬអំពើផ្សេងៗទៀត ដែលបានរៀបរាប់នៅក្នុងនោះ *ត្រូវតែទទួលការផ្ដន្ទាទោស* ទោះបីជាជននោះជាអ្នកដឹកនាំដែលជាអ្នកទទួលខុសត្រូវតាមរដ្ឋធម្មនុញ្ញក្តី ជាមន្ត្រីសាធារណៈ ឬជាបុគ្គលឯកជនក្តី[108] ។ គឺអនុសញ្ញានេះតម្រូវឱ្យភាគីដែលចុះកិច្ចសន្យាទាំងអស់ត្រូវអនុម័តច្បាប់ដែលចែងអំពី *ការដាក់ទណ្ឌកម្មដ៏មានប្រសិទ្ធិភាព*

---

[107] *Thomas Hammarberg,* "តើតុលាការខ្មែរក្រហមនឹងត្រូវបានព្រមព្រៀងគ្នាតាមរបៀបណា៖ កិច្ចពិភាក្សារវាងរដ្ឋាភិបាលកម្ពុជា និង អ.ស.ប" ។ ទស្សនាវដ្តី "ស្វែងរកការពិត" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ឆ្នាំ២០០១), *អាចរកបានតាម* http://www.dccam.org/Tribunal/Analysis/How_Khmer_Rouge_Tribunal.htm ។

[108] អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍, មាត្រា ៤ ។

ចំពោះជនទាំងឡាយដែលត្រូវមានទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយមិនថែងពីបញ្ញត្តិដែលអនុញ្ញាតឱ្យមានការប្រមាថណាមួយចំពោះកាតព្វកិច្ចទាំងនេះទេ[109] ។ អាស្រ័យហេតុនេះ ការអនុញ្ញាតផ្តល់ការលើកលែងទោសណាមួយចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាការឈានឆ្ពោះទៅរកការរំលោភបំពានចំពោះកាតព្វកិច្ចដែលឋិតក្រោមសន្ធិសញ្ញា ដែលមិនអាចឱ្យមានការអត់ឱន ឬការលើកលែងណាមួយបានឡើយ[110] ។ ការលើកសំអាងស្រដៀងគ្នានេះអនុវត្តចំពោះកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការកាត់ទោស និងផ្តន្ទាទោសក្រោមអនុសញ្ញានានានៃទីក្រុងហ្សឺណែវ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និង អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

### *(៤) អ.វ.ត.ក មិនជាប់កាតព្វកិច្ចក្នុងការអនុវត្តន៍តាមការអនុគ្រោះទោសរបស់ថ្នាក់ជាតិទេ*

៣៩. ក្នុងនាមជា "តុលាការពិសេសមួយដែលត្រូវបានធ្វើឱ្យមានលក្ខណៈអន្តរជាតិ" ដែលជាប់កាតព្វកិច្ចត្រូវអនុវត្តតាមច្បាប់អន្តរជាតិ ការអនុគ្រោះទោសណាមួយរបស់ថ្នាក់ជាតិ (ដែលទោះបីជាត្រូវបានអនុញ្ញាតផ្តល់ឱ្យដោយសុពលភាពក្តី) មិនអាចអនុវត្តចំពោះការកាត់ទោសពីបទឧក្រិដ្ឋកម្មដែលគោលការណ៍ច្បាប់អន្តរជាតិចាប់បង្ខំរដ្ឋទាំងអស់ត្រូវជាប់កាតព្វកិច្ចដោយគ្មានលើកលែងនៅចំពោះមុខតុលាការបាននេះទេ[111] ។ ការលើកលែងទោសជាក់ស្តែងគឺមិនចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ ហើយបើសិនជាត្រូវបានអនុគ្រោះទោសក៏ដោយក៏មិនអាចយកមកអនុវត្តនៅចំពោះមុខតុលាការពិសេសដែលមានតែមួយគត់ *(sui generis* Court) នេះបានដែរ[112] ។ តុលាការនេះ គឺជាស្ថាប័នកូនកាត់ដែលមានតែមួយគត់ដែលឋិតនៅក្រោមវិធាន និងនីតិវិធីដ៏ជាក់លាក់ និងមិនមែនជាផ្នែកនៅក្នុងឋានានុក្រមរបស់តុលាការ

---

[109] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, មាត្រា ៥ ។

[110] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា, មាត្រា ២៦ ។

[111] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌទី ២០ ។

[112] *ករណីរបស់ កាំង ហ្កេកអ៊ាវ,* ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់ការឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច", សំណុំ រឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១), ចុះថ្ងៃទី០៣ ធ្នូ ២០០៧, កថាខណ្ឌទី ១៨-២០ [*បន្ទាប់ពីនេះទៅហៅថា៖* "ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច"] ។

កម្ពុជានោះទេ[113] ។ អង្គបុរេជំនុំជម្រះ បានឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានលើករណីរបស់ *ឌុច* ដោយបានជាសំអាងនូវសញ្ញាបង្ហាញមួយចំនួន (a number of indicia)របស់តុលាការអន្តរជាតិ – រួមបញ្ចូលទាំងថា តុលាការនេះគឺជា "ការសម្តែងនូវឆន្ទៈរបស់សហគមន៍អន្តរជាតិ"មួយ គឺជាផ្នែកនៃ "យន្តការរបស់យុត្តិធម៌អន្តរជាតិ" និងដែលមានយុត្តាធិការដែលថា "ចូលរួមនៅក្នុងការជំនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្មអន្តរជាតិទាំងឡាយ ដែលធ្ងន់ធ្ងរជាងគេបំផុត"[114] ។ អង្គបុរេជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានថា តុលាការនេះគឺមានលក្ខណៈខុសប្លែកគ្នាមួយចំនួនពីតុលាការដទៃៗទៀតរបស់កម្ពុជា[115] ។ តុលាការនេះគឺជាស្ថាប័ន ឯករាជ្យ និងដែលដំណើរការជាលក្ខណៈស្ថាប័នឯករាជ្យ[116] ។ គឺជាតុលាការដាច់ដោយឡែកពីគេ(self-contained) ចាប់តាំងពីពេលចាប់ផ្តើមការស៊ើបសួរមក រហូតទល់ពេលកំណត់សម្រេចនៅលើបណ្តឹងឧទ្ធរណ៍នានា[117] ។ មិនមានសិទ្ធិឲ្យទៅតុលាការដទៃៗទៀតដែលស្ថិតនៅពីក្រៅវចនាសម្ព័ន្ធរបស់ខ្លួនដើម្បីពិនិត្យសើរើឡើងវិញលើសេចក្តីសម្រេចណាមួយរបស់តុលាការនេះបានឡើយ ហើយបញ្ច្រាស់មកវិញតុលាការនេះក៏មិនអាចមានសិទ្ធិដើម្បីពិនិត្យសើរើឡើងវិញលើសេចក្តីសម្រេចណាមួយរបស់តុលាការដទៃទៀតនេះបានដែរ[118] ។ នៅក្នុងតុលាការនេះ គឺរួមមានទាំងចៅក្រមជាតិផង និងចៅក្រមអន្តរជាតិផង[119] ។

៤០. អាស្រ័យហេតុនេះ ស្របតាមសេចក្តីសម្រេចរបស់តុលាការ SCSL នៅក្នុងករណីរឿងក្តីរបស់ *Kallon* ដែលត្រូវបានរកឃើញថា ការលើកលែងទោសរបស់ថ្នាក់ជាតិណាមួយចំពោះឧក្រិដ្ឋកម្មអន្តរជាតិណាមួយ គឺមិនអាចរារាំងដល់ការកាត់ទោសចំពោះបទឧក្រិដ្ឋកម្មទាំងនោះនៅចំពោះតុលាការអន្តរជាតិបានទេ ។ ការអនុគ្រោះទោសដែលធ្វើឡើងនៅក្នុងស្រុកណាមួយ

---

[113] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨-២០ ។

[114] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨-២០ ។

[115] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨ ។

[116] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៩ ។

[117] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨ ។

[118] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨ ។

[119] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, កថាខណ្ឌទី ១៨ ។

ចំពោះឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍ ដែលគោលការណ៍ច្បាប់អន្តរជាតិបង្ខំឲ្យរដ្ឋទាំងអស់ជាប់កាតព្វកិច្ចដោយគ្មានការលើកលែង (*jus cogens* crime) នោះគឺមិនអាចអនុវត្តនៅចំពោះមុខតុលាការនេះបានឡើយ[120] ៕

ដោយសេចក្តីគោរពអំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

CO-PROSECUTORS CO-PROCUREURS * D.C.C.C * C.E.T.C

**លោកស្រី ជា លាង** **លោក** Robert PETIT

[120] សេចក្តីសម្រេចលើករណីរបស់ Kallon, កថាខណ្ឌទី ៨៦ ។